CSC
Formation, Dialogue, Cooperation

# អ្នកនាំសារ
The Messenger

កាសែតចេញផ្សាយប្រចាំខែ ឆ្នាំទី៨ សម្រាប់ខែកញ្ញា ឆ្នាំ២០១៦ លក់តម្លៃ ១០០០រៀល

លេខ ៩៦




ថតដោយ លីហៀង

## សេចក្ដីជូនដំណឹង

" លោហិតមរណសាក្សី គឺគ្រាប់ពូជរបស់ព្រះសហគមន៍ " (Apologeticus, Chapter 50:Tertullian)។ បងប្អូន ជាទីស្រឡាញ់ ព្រះសហគមន៍កាតូលិកកម្ពុជារីកចម្រើនដោយសារឈាមមរណសាក្សី។ ខ្ញុំលោកបូជាចារ្យ រឿង ឆ័ត្រសិរី អ្នករៀបចំសំណុំរឿង (Postulator) បានប្រមូលព័ត៌មានមួយចំនួនហើយ ប៉ុន្តែសូមបងប្អូនជួយផ្ដល់ព័ត៌មានបន្ថែម អំពីអ្នកបម្រើរបស់ព្រះជាម្ចាស់ថែមទៀតដូចជា រូបថត អត្ថបទ ឬសៀវភៅដែលគាត់សរសេរវត្ថុអនុស្សាវរីយរបស់គាត់ ខ្លះ។ល។ សូមផ្ដល់ឈ្មោះអ្នកដែលអាចផ្ដល់សក្ខីភាពបានជូនមកខ្ញុំតាមរយៈអាសយដ្ឋានខាងក្រោម

Tel : 077 800 211 / 096 34 22 144
ប្រអប់សំបុត្រលេខ ១២៣ រាជធានីភ្នំពេញ
Email: martyrscambodia@gmail.com

# រូបភាពប្រចាំខែ



ការចោលសំរាមរបស់ប្រជាពលរដ្ឋនៅជុំវិញផ្សារអូរឫស្សី
នាទីក្រុងភ្នំពេញ ថតដោយ រិទ្ធី



ប្រជាពលរដ្ឋមកចុះឈ្មោះបោះឆ្នោតនៅមណ្ឌលឫស្សីកែវ
កាលពីថ្ងៃទី០៤ សីហា ២០១៦ ថតដោយ សម្ផស្ស





កាកសំណល់ផ្លាស្ទិកនៅអាហារដ្ឋាន ផ្សារទំនើប អ៊ីអនម៉ល (Aeon Mall)
ថតដោយ កញ្ញា


CSC
Formation, Dailouge, Cooperation

ការិយាល័យផ្សព្វផ្សាយព័ត៌មានកាតូលិក



ផ្ទះលេខ ២៥ ផ្លូវលេខ ២៤២ សង្កាត់ បឹងព្រលិត ខណ្ឌ ៧ មករា រាជធានីភ្នំពេញ

Tel/Fax : (855) 23 224 120

Email : csccambodia@gmail.com / Website : www.catholiccambodia.org



ចាងហ្វាង : លោក លី សុវណ្ណា

សេចក្តីប្រកាសលេខៈ ១០១ ព.ម.ប្រ.ក/ ០៥-កុម្ភៈ-២០១៤

# កម្ពុជាកំពុងតែទទួលភាពលេចធ្លោនៅក្នុងវិស័យការទូតនៅអាស៊ាន

បើនិយាយអំពីអាស៊ានកម្ពុជា គឺជាកូនពៅនៅពេលនេះ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ កូនពៅមួយនេះ បានបង្កនូវភាពលេចធ្លោរខាងនយោបាយការទូតតំបន់មួយដ៏អស្ចារ្យដែលអាចនឹងឲ្យបណ្ដាកូនច្បងនានាមានការភ្ញាក់ផ្អើលបាន។

អាស៊ានបានបង្កើតឡើងនៅក្នុងថ្ងៃទី០៨ សីហា ១៩៦៧ ហើយកម្ពុជាទើបតែចាប់កំណើតនៅក្នុងផ្ទៃអាស៊ាន នៅថ្ងៃទី៣០ មេសា ១៩៩៩ តែប៉ុណ្ណោះ ប៉ុន្តែ ១៧ ឆ្នាំ នៅក្នុងសណ្ដានការទូតនៅអាស៊ាន កម្ពុជាបានបង្កនូវភាពភ្ញាក់ផ្អើលដ៏សម្បើមជាបន្តបន្ទាប់ ឲ្យកូនច្បងៗ អាស៊ានបានភ្លឹភ្នែក។

កម្ពុជារស់នៅក្រោមផ្ទៃនៃអាស៊ាន តែ ១៧ឆ្នាំទេ ប៉ុន្តែកម្ពុជានៅក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ កម្ពុជាបានលេងល្បែងការទូតមួយនៅក្នុងអាស៊ាន ដែលនរណាក៏បានស្គាល់ និងកត់សំគាល់អំពីនយោបាយការទូតកម្ពុជា ។

នៅក្នុងឋានៈខ្លួនជាកូនពៅរបស់អាស៊ានពោលគឺតាំងពីឆ្នាំ២០០២ ដែលខ្លួនបានធ្វើជាប្រធានអាស៊ាន កម្ពុជាបានចាប់យកចំណុចក្ដៅមួយនៅអាស៊ាន គឺជាចំណុចលេចធ្លោរ គឺនយោបាយនាំអាស៊ានគេចចេញពីជម្លោះទឹកដីរវាងប្រទេសអាស៊ានមួយចំនួនដែលរួមមាន ហ្វីលីពិន វៀតណាម ប្រ៊ុយណេ និងម៉ាឡេស៊ី ចេញពីជម្លោះទឹកដៅនៅសមុទ្រចិនខាងត្បូង ជាមួយចិន។

ក្រោយមកនៅក្នុងឋានៈកម្ពុជាជាប្រធានអាស៊ានវិលជុំជាថ្មីនៅក្នុង ឆ្នាំ២០១២ នៅក្នុងខណៈពេលដែល ប្រទេសមួយចំនួននៅក្នុងវិបត្តិ គ្រោងនឹងជំរុញឲ្យអាស៊ានទាំងមូលលូកដៃចូលទៅក្នុង ជម្លោះទ្វេភាគីរវាងប្រទេសអាស៊ាន និងចិននៅសមុទ្រចិនខាងត្បូងជាមួយចិន។

ប្រទេសកម្ពុជា ដែលជាកូនពៅនៃអាស៊ានបានប្រើឋានៈរបស់ខ្លួនជាប្រធានដ៏ឈ្លាសវៃ ដើម្បីដឹកនាំអាស៊ាន ឲ្យគេចចេញពីជម្លោះ រវាងចិន និងអាស៊ាន មួយចំនួនខាងលើជាថ្មី។ នៅក្នុងឆ្នាំនោះ អ្នកការទូត អ្នកជំនាញកិច្ចការអន្តរជាតិជាច្រើន សុទ្ធតែអះអាងសុទ្ធតែរិះគន់កម្ពុជានៅក្នុងការប្រកាន់ជំហរមួយច្បាស់លាស់លើបញ្ហាជម្លោះទឹកដី នៅសមុទ្រចិនខាងត្បូងនេះ ដែលជាលើកទីមួយដែលអាស៊ានបញ្ចប់កិច្ចប្រជុំមួយ ដែលគ្មានសេចក្ដីថ្លែងការណ៍រួម។ គេចាំបានថា នៅពេលនោះនរណាក៏សើចហើយចំអន់កម្ពុជាប៉ុន្តែការតស៊ូមតិជាបន្តបន្ទាប់នៅក្នុងបណ្ដាកិច្ចប្រជុំនានា ទោះបីជាកម្ពុជាត្រូវរងនូវសម្ពាធនៃសង្គ្រាមវោហាសព្ទការទូត ពីក្រុមប្រទេសមានជម្លោះ និងអ្នកជំនាញការកិច្ចការបរទេសក្រៅតំបន់នានា ជាបន្តបន្ទាប់ក៏ដោយក៏កម្ពុជានៅតែបង្ហាញជំហរមួយដដែល ជុំវិញបញ្ហាជម្លោះទឹកដៅនៅសមុទ្រចិនខាងត្បូងនេះ ដោយជំរុញឲ្យប្រទេសដែលពាក់ព័ន្ធដោះស្រាយជម្លោះនៅក្នុងកម្រិតទ្វេភាគីទៅតាម ច្បាប់អន្តរជាតិនានាជាពិសេស គឺអនុវត្តទៅតាមសេចក្ដីថ្លែងការណ៍ ស្ដីពីការអនុវត្ត នៃគូភាគីនៅក្នុងសមុទ្រចិនខាងត្បូង (DOC) និងជម្រុញឲ្យចេញនូវក្រមប្រតិបត្តិ សមុទ្រចិនខាងត្បូងនេះ (COC)។

នៅក្រោយពេលដែលហ្វីលីពិនបាននាំយកជម្លោះនេះ ទៅតុលាការមជ្ឈត្តិការអន្តរជាតិនៅក្នុងទីក្រុងឡាអេមកដោះស្រាយ និងចេញសាលក្រមដោយអះអាងថា ចិនគ្មានសិទ្ធិនៅលើទឹកដីនោះកាលពីពេលថ្មីៗនេះ បានបង្កឲ្យកិច្ចប្រជុំរដ្ឋមន្ត្រីកាបរទេសអាស៊ាននិងចិននៅប្រទេសចិន ប្រទាយប្រទង់គ្នាជាថ្មី ហើយគេរំពឹងថា នឹងអាចប្រទាយប្រទង់ទៀតនៅក្នុងពេល ដែលឡាវធ្វើជាម្ចាស់ផ្ទះកិច្ចប្រជុំកំពូលនៅទីក្រុងវៀងច័ន្ទ ប៉ុន្តែផ្ទុយទៅវិញ កិច្ចប្រជុំកំពូលនេះបានបញ្ចប់ដោយជោគជ័យ ហើយកម្ពុជាក៏ទទួលបានផ្លែផ្កានៃនយោបាយការទូត លើបញ្ហានេះក្រោយពេលដែលពាក់ព័ន្ធមកតាំងតែពីឆ្នាំ ២០០២មកនោះ ។

នៅក្នុងកិច្ចប្រជុំកំពូលដែលទើបតែបញ្ចប់ទៅកាលពីពេលថ្មីៗនេះ ប្រទេសហ្វីលីពិនដែលធ្លាប់តែ ប៉ះនិងប្រតិកម្មខ្លាំងនឹងនយោបាយការទូតកម្ពុជាជុំវិញជម្លោះនៅសមុទ្រចិនខាងត្បូង បានសម្របសម្រួលកិច្ចការនេះ។ ចុងក្រោយកិច្ចប្រជុំនេះបានបញ្ចប់ជាមួយនឹងសេចក្ដីថ្លែងការណ៍រួមមួយ ដែលគេអាចមើលទៅឃើញលទ្ធផល នៃកិច្ចប្រជុំប្រកដោយផ្លែផ្កា ។

ឈានចេញពីសេចក្ដីថ្លែងការណ៍ស្ដីពីការអនុវត្ត នៃគូភាគីនៅក្នុងសមុទ្រចិនខាងត្បូង DOC ដែលកម្ពុជាតែងតែគាំទ្រនោះ គឺ មេដឹកនាំអាស៊ានក៏បានអនុម័តនូវ កម្មវិធីនៃក្រមប្រតិបត្តិសម្រាប់ហេតុការណ៍ដែលអាចប៉ះទង្គិចដោយមិនបានគ្រោងទុក នៅសមុទ្រដែលហៅកាត់ថា CUES នៅសមុទ្រចិនខាងត្បូង និងគោលការណ៍នៃការបង្កើតខ្សែទំនាក់ទំនងនៅក្នុងចំណោមមន្ត្រីជាន់ខ្ពស់អាស៊ាននិងចិន នៅក្នុងការឆ្លើយតបនឹង ហេតុការណ៍បន្ទាន់នៅសមុទ្រ ថែមទៀតផងដែរ ។

នៅក្នុងកិច្ចប្រជុំកំពូលលើកនេះ អាស៊ាននិងចិនក៏បានសន្យាថា នឹងជំរុញការផ្លាស់ប្ដូរពាណិជ្ជកម្ម ដែលមានតម្លៃ ៣៤៦,៤ ពាន់លានដុល្លារ និងការបណ្ដាក់ទុន ប្រមាណជា ៨,២ពាន់លានដុល្លារ នៅក្នុងឆ្នាំ២០១៥ ឲ្យទៅដល់ ១ទ្រីលានដុល្លារ និង១៥០ ពាន់លានដុល្លារនៅឆ្នាំ២០២០ ខាងមុខនេះ ។

សរុបមកវិញ នេះ ទាំងនេះគឺជាការរួមចំណែកមួយដ៏ធំដល់អាស៊ាននៅក្នុងឋានៈកម្ពុជាដែលនរណាក៏ដឹងថា គឺជាប្រទេសដែលមានទំនាក់ទំនងដ៏ជិតស្និតជាមួយនឹងប្រទេសចិន បើប្រៀបធៀបជាមួយនឹងបណ្ដាប្រទេសនានានៅក្នុងតំបន់នេះ ។

# ព្រះសហគមន៍កាតូលិកកម្ពុជាយកចិត្តទុកដាក់លើរបាំខ្មែរ

សិក្ខាសាលា រយៈពេលជិត ពីរសប្ដាហ៍អំពីរបាំខ្មែរ ដែលរៀបចំដោយ ការិយាល័យសិល្បៈ និងវប្បធម៌ ព្រះសហគមន៍កាតូ-លិកភូមិភ្នំពេញ បានបិទបញ្ចប់វគ្គរបស់ខ្លួន កាលពីនៅថ្ងៃទី១២ សីហា ២០១៦។ សិក្ខាសាលានេះប្រព្រឹត្តទៅ ពីថ្ងៃទី ៣១ ខែកក្កដា ដល់ថ្ងៃទី១២ ខែសីហានេះ នៅព្រះវិហារ សន្តសិលា និងសន្តប៉ូល ក្នុងសង្កាត់ភ្នំពេញថ្មី ដែលមានសិក្ខាកាមចូលរួមចំនួន១០៣ មកពីព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។

អ្នកស្រី សួន ប៊ុណ្ណារ៉េត នាយិកាសាលារបាំបុរាណ និងភ្លេងខ្មែរ នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ បានឲ្យដឹងថា សិក្ខាសាលានេះគឺចង់បណ្ដុះបណ្ដាលឲ្យក្មេងៗ និងយុវជននៅតាមព្រះសហគមន៍ យល់ច្បាស់អំពីរបៀបពត់ដៃជើងក្បាច់រាំរបាំខ្មែរដើម្បីស្វែងកេរមរតកដូនតាអំពីក្បាច់របាំបុរាណខ្មែរ ហើយអាចមានសមត្ថភាពបង្ហាញ តាមរយៈកម្មវិធីផ្សេងៗនៅក្នុងព្រះសហគមន៍។

ព្រះសហគមន៍កាតូលិកសកលបានអនុញ្ញាតឲ្យព្រះសហគមន៍កាតូលិកក្នុងប្រទេសនិយាយប្រើប្រាស់វប្បធម៌ ភាសារបស់អ្នកស្រុក ដើម្បីលើកតម្កើងព្រះ-ជាម្ចាស់។ ព្រះសហគមន៍កាតូលិកនៅកម្ពុជាបានខិតខំយ៉ាងខ្លាំងក្នុងការថែរក្សានិងអប់រំបន្តជាពិសេសរបាំខ្មែរ ដល់យុវជនជំនាន់ក្រោយ ព្រមទាំងប្រើប្រាស់មរតកទាំងនោះដើម្បីសរសើរតម្កើងស្នាព្រះហស្តរបស់ព្រះជាម្ចាស់។

លោកបូជាចារ្យ វង្សម៉ាសែន ហាតាផៃ តំណាងឲ្យមណ្ឌលសិល្បៈនិងវប្បធម៌ភូមិភាគភ្នំពេញបានមានប្រសាសន៍ថា សិល្បៈរបាំបុរាណខ្មែរ គឺជាគន្លឹះមួយដែលជួយដល់ព្រះសហគមន៍ក្នុងការប្រកាសដំណឹងល្អតាមរយៈរបាំ ហើយមានយុវជនយុវ-នារី និងកុមារជាច្រើនមានការចាប់អារ-ម្មណ៍។ លោកថាជាក់ស្ដែង នៅមណ្ឌលសកម្មភាពតាកែវ ជាពិសេសព្រះសហ-



គមន៍ព្រែកកប្បាស អ្នកភូមិបានស្គាល់ព្រះសហគមន៍ច្រើនក៏ដោយសារសិល្បៈនេះផងដែរ។

បន្ទាប់ពីអភិបូជា ក្រុមសិក្ខាកាមទាំងអស់បានបង្ហាញស្នាដៃរបស់គេ នូវរបាំដែលពួកគេបានរៀនសូត្ររយៈពេលជាង ១០ថ្ងៃដល់មហាជនដែលបានចូលរួមក្នុងពិធីបិទវគ្គសិក្ខាសាលានេះ។

ការិយាល័យ របាំបុរាណ និងវប្បធម៌នៃព្រះសហគមន៍កាតូលិកភូមិភាគភ្នំ-ពេញ បានកកើតឡើងកាលពីចុងឆ្នាំ ២០១៣ និងបានរៀបចំសិក្ខាសាលាបានចំនួនបួនដងរួចមក ហើយនេះជាលើកទីប្រាំដែលមានយុវជន និងកុមារមកពីព្រះសហគមន៍កាតូលិកទាំងបីភូមិភាគ។

*ដោយ : ដាលីស*

# ត្រួសៗពីសម្ទុះនៃសេដ្ឋកិច្ចនៅឆមាសទីមួយឆ្នាំ២០១៦

សេដ្ឋកិច្ចកម្ពុជានាឆ្នាំ ២០១៦ នេះ ត្រូវបានគេព្យាករណ៍ថា នឹងបន្តរីកចម្រើន ជាមួយនឹងកំណើនសេដ្ឋកិច្ចប្រកបដោយភាពរីជ្ជមានបន្តទៀត។

ផ្អែកលើ ស្ថានភាពនៃភាពវិជ្ជមាននេះ សន្ទស្សន៍នៃវិស័យសំខាន់ៗដែលជំរុញកំណើនសេដ្ឋកិច្ចដូចជា វិស័យហិរញ្ញវត្ថុ សំណង់.. នារយៈពេល ពី ៦ ទៅ៧ ខែគឺបង្ហាញពី និន្នាការទៅតាមការព្យាករណ៍នោះ។

លោកជា ចាន់តូ ទេសាភិបាលធនាគារជាតិនៃកម្ពុជា បានឲ្យដឹងនៅពាក់កណ្តាលខែសីហា ឆ្នាំ២០១៦ នេះថា អត្រាអតិផរណានៅកម្ពុជាមានកម្រិតត្រឹមតែ ២,៨ភាគរយ ប៉ុណ្ណោះ នៅឆមាសទី១ ឆ្នាំ២០១៦ នេះ ដោយឡែកអត្រាប្តូប្រាក់វិញ គឺនៅក្នុងរង្វង់ ៤.០៤៤ រៀលក្នុងមួយដុល្លារ ។

លោកបានបន្តថា នៅក្នុងរយៈពេលនេះទុនបម្រុងអន្តរជាតិបានកើនដល់ ៥,៥ ពាន់លានដុល្លារ ហើយទ្រព្យសកម្មរបស់ប្រព័ន្ធធនាគារបានកើនឡើងដល់ ២,២ ពាន់លានដុល្លារ បានធ្វើឲ្យទ្រព្យសកម្ម សរុបកើនឡើងប្រមាណជា ២៦ពាន់ លានដុល្លារ ប្រាក់បញ្ញើកើន៦៧ ភាគរយ ហើយឥណទាន កើន៨០ភាគរយ។

តាមទស្សនាទាននេះ ធនាគារជាតិនៃកម្ពុជាបានរំពឹងថា កម្ពុជាអាចនឹង ទទួលកំណើនសេដ្ឋកិច្ចនៅក្នុងរង្វង់៧,១ ភាគរយនាឆ្នាំ២០១៦នេះ ជាមួយនឹងអត្រាអតិផរណា ៣ភាគរយ ហើយលុយរៀលនឹងបន្តស្ថេរភាពនៅក្នុងកម្រិត៤.០៥០ រៀល។

នៅក្នុងរយៈពេលឆមាសទីមួយដើមឆ្នាំ២០១៦ កន្លងទៅនេះសកម្មភាពសេដ្ឋកិច្ចកម្ពុជានៅលើផ្លូវវិជ្ជមានជាបន្តទៀត។ នេះបើផ្អែកទៅតាមស្ថិតិដែលត្រូវបានផ្សព្វផ្សាយដោយស្ថាប័នជំនាញនានា នាពេលកន្លងមក ។

នៅក្នុងរយៈពេលពីខែមករាដលកក្កដា វិស័យសំណង់ត្រូវបានគេដឹងថា មានកំណើនកើនឡើងដូចរ៉ូកែត ដោយទឹកប្រាក់វិនិយោគលើវិស័យសំណង់បានកើនពី៨៩៩លានដុល្លារ នៅ៧ខែ ឆ្នាំ២០១៥ ទៅដល់ ៧.១០៨ លានដុល្លារនៅ រយៈពេល៧ខែ ឆ្នាំ២០១៦ ពោល គឺកើនឡើង ៧១៩,៣៩ ភាគរយ។

ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានឲ្យដឹងថា គម្រោងដែលបានស្នើសុំសាងសង់នៅក្នុងរយៈពេលនេះ គឺមានទាំងអស់ ១.៥០០ គម្រោង នៅលើផ្ទៃក្រឡា ប្រមាណជា ១១ លានម៉ែត្រការ៉េ ខណៈដែលកាលពីរយៈពេលដដែលឆ្នាំទៅ គឺមាន ១.០៨៣គម្រោង ទំហំ ២,៧ លានម៉ែត្រការ៉េ ។

ដោយឡែកវិស័យទេសចរណ៍ វិញ ឃើញថា ហាក់មានសភាពមិនសូវជាស្ទុះស្ទាខ្លាំងប៉ុន្មានឡើយ ដោយសារតែការគំរាមកំហែងនៃភេរវកម្ម និងស្ថានភាពទូទៅមួយចំនួន ។

ក្រសួងទេសចរណ៍បានប្រកាស នៅឆមាសទីមួយឆ្នាំ២០១៦នេះ វិស័យទេសចរណ៍កម្ពុជាបានទាក់ទាញ ភ្ញៀវទេសចរបរទេស បានសរុបចំនួន ២,៣៦ លាននាក់ពោល គឺមានកំណើនកើនឡើងត្រឹមតែ ២,៦ភាគរយ តែប៉ុណ្ណោះ។

នៅក្នុងរយៈពេលនេះ ភ្ញៀវទេសចរបរទេសធំៗដែលមកលំហែនៅកម្ពុជាគឺវៀតណាម មានចំនួន ៤៦១.៧៦១ កើនឡើង ១៩,៦ភាគរយ ចិននៅលំដាប់ទី២ ចំនួន ៣៧៨.៧៣៧ កើន១៦ភាគរយ កូរ៉េចំនួន ១៩២.៩៩៨នាក់ កើន ៨,២ ភាគរយ ។

ដោយឡែកការនាំចេញរបស់ប្រទេសកម្ពុជាក៏ស្ថិតនៅលើផ្លូវវិជ្ជមាន ផងដែរ ដោយតួលេខរបស់ក្រសួងពាណិជ្ជកម្ម បានអះអាងថា ការនាំចេញនៅឆមាសទីមួយនៃឆ្នាំ២០១៦នេះ គឺមានទឹកប្រាក់ ៤,៥៦ពាន់លានដុល្លារកើនឡើងជាង ១០ភាគរយ បើធៀបនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន ប៉ុន្តែការនាំចូល គឺមានតម្លៃប្រមាណជា ៦,៣៣ ពាន់លានដុល្លារ កើនឡើងជាង ១២ភាគរយ។

នៅក្នុងរយៈពេលនេះផលិតផលដែលនាំមុខគឺនៅតែជាផលិតផលវាយនភ័ណ្ឌ និងកាត់ដេរ ក្រៅពីនោះ គឺកសិផលដែលមានដូចជា អង្ករ ស្ករស កៅស៊ូ ម្រេច។ រីឯផលិតផលនាំចូលគឺ ជាវត្ថុធាតុដើមសម្រាប់គាំទ្រឧស្សាហកម្មកាត់ដេរ អាហារ គ្រឿងអេឡិចត្រូនិច ឱសថ គ្រឿងសំអាងភេសជ្ជៈ សារធាតុគីមី និងប្រេងឥន្ធនៈជាដើម។ ចំពោះវិស័យការងារវិញ លោក អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានប្រកាស នៅលើ បណ្តាញសង្គមរបស់លោកថា គិតដល់ខែកក្កដា ឆ្នាំនេះ ក្រសួងបានបង្កើតការងារថ្មី ដល់ប្រជាពលរដ្ឋបានចំនួន ៧.៥០០ កន្លែង។

លោកបានអះអាងថា នៅទូទាំងកម្ពុជាមានសហគ្រាសគ្រឹះស្ថានសរុបមានចំនួន ៦.៧៤២ រួមមានរោងចក្រកាត់ដេរ និងផលិតស្បែកជើង១,០២៧ និងមានកម្ម-ករនិយោជិត បម្រើការងារចំនួន ១.១១៨.១៧៥នាក់ នៅក្នុងនោះ សហគ្រាសគ្រឹះស្ថានបើកថ្មីមានចំនួន ៥៧ ដោយរោងចក្រកាត់ដេរ និងផលិតស្បែកជើងមានចំនួនរហូតដល់ទៅ ២០។

ក្រៅពីវិស័យទាំងនេះវិស័យធានារ៉ាប់រងនៅកម្ពុជាក៏បានបង្ហាញពីការកើនឡើងផងដែរជាមួយនឹងកំណើនប្រមាណជា ៣៧ភាគរយ នៅឆមាសទីមួយឆ្នាំ ២០១៦ នេះ។

សមាគមធានារ៉ាប់រងកម្ពុជា បានផ្សព្វផ្សាយថា នៅឆមាសទី១ ដើមឆ្នាំនេះ បុព្វលាភធានារ៉ាប់រងនេះបានកើនឡើងពី ៤០,៩លានដុល្លារនៅឆមាសទីមួយឆ្នាំ២០១៥ ខណៈឆមាសទី១ ដើមឆ្នាំ ២០១៦ គឺមានទំហំ ៥៦លានដុល្លារ។

*ដោយ : អរិយបុត្រ*



*ថតដោយៈ សម្បត្តិ*

# យុវជនកម្ពុជាចាប់អារម្មណ៍នឹង ហ្គេម ប៉ូគេម៉ន ហ្គោ ប៉ុន្តែមិនជាផុលផុស




*ថតដោយ លីហៀង*

ខណៈដែលប្រទេសជិតខាងមានដូចជា វៀតណាម និងថៃ មានសារព្រមានពីសំណាក់អាជ្ញាធរមាន សមត្ថកិច្ច ហើយនោះ នៅក្នុងប្រទេសកម្ពុជា យុវជនកំពុងតែចាប់អារម្មណ៍ នឹងហ្គេមថ្មី ប៉ូគេម៉ន ហ្គោ (Pokemon Go) នេះដែរ តែ ហាក់ដូចជាមិនទាន់ផុលផុសនៅឡើយទេ។

ហ្គេមថ្មីនេះ ត្រូវបានបណ្តាញព័ត៌មានចេញផ្សាយជាបន្តបន្ទាប់ថា គឺជាហ្គេមមួយដែលល្បី ហើយពេញនិយម ប៉ុន្តែហ្គេមនេះគឺជាល្បែងមួយដែលអាចនាំឲ្យអ្នកលេងមានគ្រោះថ្នាក់ដោយសារតែការងប់ងល់នឹងហ្គេមនេះខ្លាំងពេក។

កញ្ញា សាញ់ កញ្ញានា ជាយុវតីម្នាក់បានអះអាងនៅហាងកាហ្វេមួយនៅក្នុងរាជធានីភ្នំពេញថា កញ្ញចាប់អារម្មណ៍នឹងហ្គេមនេះដែរ ប៉ុន្តែនៅមិនទាន់បាន ទាញចេញយកមកដាក់នៅក្នុងទូរស័ព្ទ (Download) របស់នាងនៅឡើយទេ ។

កញ្ញា បានបញ្ជាក់ថា "ខ្ញុំចាប់អារម្មណ៍ប៉ុន្មានខែហើយ ក្រោយពេលដែលអានព័ត៌មាន នៅលើបណ្តាញសង្គម អំពីប៉ូគេម៉ន ហ្គោនេះ "។

កញ្ញា បានបន្តថា បើតាមព័ត៌មានដែលកញ្ញាបានទទួល ការលេងហ្គេមថ្មីនេះ គឺមានទាំងគុណសម្បត្តិ និងគុណវិបត្តិ។ កញ្ញា បានបន្តថា អ្នកលេងហ្គេមនេះ អាចចេះរបៀបមើលផែនទីចេះចេញប្រើប្រព័ន្ធជីភីអេស (GPS) ហើយអាចមានចលនាជាប្រចាំ ជាហេតុអាចឲ្យអ្នកលេងមានសកម្មភាព មិនងប់ងុល នឹងការងារខ្លាំងហួតអង្គុយតែនៅក្នុងការិយាល័យ ហើយមិនតែប៉ុណ្ណោះតែវាអាចជួយកាត់បន្ថយភាពតានតឹងបានថែមទៀត ប៉ុន្តែវាអាចជាប្រភេទហ្គេម ដែលនាំយើងឲ្យធ្វើអំពើផ្តេសផ្តាស រវើរវាយ ហើយអាចនឹងមានគ្រោះថ្នាក់ដល់ខ្លួនដូចជា នាំអ្នកលេងទៅចូលកន្លែងហាមឃាត់ ឬកន្លែងគ្រោះថ្នាក់ ហើយក៏អាចជាហ្គេមមួយដែលនាំអ្នកលេងទៅរំលោភសិទ្ធិឯកជនរបស់គេផងក៏ថាបាន ។

កញ្ញា បានបញ្ជាក់ថា "នេះគឺជាអ្វីដែលខ្ញុំបានដឹង តែខ្ញុំក៏មិនដឹងយ៉ាងម៉េចដែរ ព្រោះមិនទាន់បានសាក។

ហ្គេមប្រភេទនេះល្បីណាស់នៅលោកខាងលិច ជាពិសេសនៅ សហរដ្ឋអាមេរិកជាដើម ដោយឡែក នៅប្រទេសវៀតណាម និងថៃ គឺទើបមកដល់ ប៉ុន្តែក៏មានការពេញនិយមផងដែរ ប៉ុន្តែនៅកម្ពុជា អាចមានអ្នកដែលបានសាកល្បងលេងហ្គេមនេះ ប៉ុន្តែ"អ្នកនាំសារ" នៅមិនទាន់អាចរកអ្នកដែលបានលេងហ្គេមនេះផ្ទាល់នៅឡើយទេ។ ម្នាក់ៗដែលបានសំភាសន៍គឺបានត្រឹមតែទទួលព័ត៌មាន ប៉ុន្តែនៅមិនទាន់សាកល្បងលេងហ្គេមនេះនៅឡើយទេ។

យុវជន ឃិត សុបញ្ញា ជានិស្សិតឆ្នាំទីពីរដែលកំពុងតែសិក្សាបរិញ្ញាប័ត្រស្ថាបត្យកម្ម បានអះអាងថា ហ្គេមនេះរូបគេបានឮយូរហើយ ប៉ុន្តែមិនទាន់បានសាកល្បង ហើយមិត្តភក្តិរបស់គេ ក៏នៅមិនទាន់ មាននរណាបានលេងហ្គេមនេះនៅឡើយទេ ។

យុវជនរូបនោះ បានអះអាងថា "ខ្ញុំឮតែគេនិយាយ ប៉ុន្តែមិនទាន់សាកល្បងលេងនឹងគេនៅឡើយ ហើយមិត្តភ័ក្រខ្ញុំក៏ដូចជាមិនទាន់មានអ្នក ទាញចេញពីផ្លេស្តរ(Playstore)មកលេងនៅឡើយទេ ពេលនេះ "។

សុបញ្ញា បានអះអាងថា នៅពេលទទួលព័ត៌មានអំពីហ្គេមនេះ រូបគេធ្លាប់ចង់សាកល្បង ហើយបានចូលទៅផ្លេស្តរ ប៉ុន្តែមិនដឹងជាទៅទាញចេញហ្គេមមួយណា ដោយសារតែនៅក្នុងផ្លេស្តរនេះមានអេប (App) នៃហ្គេមដែលមានឈ្មោះថា ប៉ូគេម៉ន នេះច្រើនសន្ធឹក។

សុបញ្ញាបានបញ្ជាក់ថា "ពេលឃើញអេប ច្រើនដូច្នេះ មិនដឹងជាទាញមួយណាក៏ទុកសិនរហូតដល់ពេលនេះ។

បើតាម សុបញ្ញា គឺរូបគេធ្លាប់បានចូលទៅ ផ្លេស្តរ ដើម្បីរកហ្គេមនេះ ប្រហែលជា ២ទៅ ៣ខែ ហើយ ប៉ុន្តែឥឡូវក៏នៅចង់សាកល្បងលេងដែរ ប៉ុន្តែមិនទាន់មានឱកាស។

យុវជនមួយរូបទៀត ដែលកំពុងតែឈ្ងោកមើលស្មាតហ្វូនរបស់ខ្លួននៅលើម៉ូតូនៅមុខ វិទ្យាល័យ ទួលទំពូង ពេលកំពុងរង់ចាំប្អូនមើលឈ្មោះប្រឡង បានឲ្យដឹងថា ប្អូនបានឃើញ ប៉ូគេម៉ន ហ្គោនៅលើអេបស្តរ (AppStore) អាយហ្វូនរបស់ប្អូនហើយ ប៉ុន្តែក៏នៅមិនទាន់បានលេង ឬទាញចេញមកលេងនៅឡើយទេ។

ជិញ លីហេង ជាយុវជនដែលមានវ័យប្រហែលជា ជាង ២០ឆ្នាំ បាននិយាយថា លោកជឿថា នៅភ្នំពេញមានអ្នកលេងហ្គេមនេះ ប៉ុន្តែប្អូន ហាក់មិនចាប់អារម្មណ៍ដោយសារតែវាដូចជា មិនត្រូវចំណាប់អារម្មណ៍ ។

លីហេង បានបញ្ជាក់ថា "ថ្មីៗនេះ ខ្ញុំឃើញវាលោតភ្លឹបៗនៅអេបស្តូ ប៉ុន្តែមិនចាប់អារម្មណ៍លេងទេ ដោយសារតាមស្តាប់ទៅ វាស៊ីលុយច្រើនណាស់ ព្រោះវាជាហ្គេមអនឡាញ ហើយត្រូវបើកតាំងពីជីភីអេស ហើយក៏ត្រូវការអ៊ីនធើណែតមួយដែលមានល្បឿនលឿនថែមទៀត"។

លីហេង និយាយថា "បើលេងហ្គេមនេះ មើលទៅក្រតែម្តង"។ លីហេង បានអះអាងថា នៅពេលនេះហ្គេម ប្អូនចូលចិត្តលេង គឺជាប្រភេទហ្គេមដែលបាញ់គ្នាដូចជា មានការសាងសង់បន្ទាយ ហ្គេមបែបកសិដ្ឋាន និងមានការរិះគិត ច្រើនជាង... ។ល។

ជុំវិញហ្គេម ប៉ូគេម៉ន ហ្គោ នេះអាជ្ញាធរនៅក្នុងប្រទេសថៃ បានជូនដំណឹងថាអាជ្ញាធរនឹងចាត់វិធានការផ្លូវច្បាប់ចំពោះអ្នកបើកបរយានយន្តណា ដែលបើកបរបណ្តើរ ហើយលេងហ្គេមនេះបណ្តើរក្រោយពេលដែលមានបាតុភាពស្ទះចរាចរណ៍ដោយសារតែ មានរបាយការណ៍ថា មានអ្នកលេងហ្គេមនេះ ឈប់ឡានហើយ អនុវត្តលេងហ្គេមនេះរហូតដល់ស្ទះចរាចរណ៍។ ដោយឡែកនៅក្នុងប្រទេសវៀតណាម អាជ្ញាធរបានចេញបម្រាមហាមលេងហ្គេមនេះ នៅកន្លែងរដ្ឋ កន្លែងសន្តិសុខមួយចំនួន ដោយសារតែការបារម្ភអំពីបញ្ហាសន្តិសុខ និងសណ្តាប់ធ្នាប់។

កាលពីថ្ងៃច័ន្ទ ទី២២ ខែសីហា ប៉ូលិសក្រុងបាងកកបានប្រកាសបង្ក្រាបអ្នកបើកបរណាដែលលេងហ្គេម ប៉ូគេម៉ន ហ្គោ បន្ទាប់ពីមានការប្តឹងត៉វ៉ាថា ល្បែងមួយនេះកំពុងធ្វើឱ្យចរាចរណ៍ដែលស្ទះស្រាប់គាំងលែងទៅមុខ។ ហ្គេមទូរស័ព្ទ ដែលជំរុញឱ្យអ្នកលេងដើរតាមផ្លូវដើម្បីស្វែងរកបិសាចឌីជីថលនេះ បានដាក់ឱ្យលេងនៅប្រទេសថៃកាលពីដើមខែនេះ ដោយធ្វើឱ្យ មនុស្សជាច្រើនសប្បាយចិត្តឥតឧបមា។ ប៉ុន្តែបាងកកមិនមែនជាកន្លែងស័ក្តិសមសម្រាប់លេងហ្គេមដេញចាប់បិសាចឌីជីថនេះទេ។ ហ្គេមនេះតម្រូវឱ្យមនុស្សបើក GPS និងអ៊ីនធឺណេតទូរស័ព្ទទើបអាចលេងបាន និងត្រូវឱ្យតាមចាប់សត្វបិសាចក្នុងហ្គេម ដែលរត់សព្វទីកន្លែងក្នុងផែនទី ដែលបង្ហាញក្នុងតំបន់ដែលមនុស្សកំពុងលេង។ វាអាចនាំមនុស្សទៅគ្រប់កន្លែង មិនថាបន្ទាយទាហានមន្ទីរពេទ្យ សារមន្ទីរ ឬកន្លែងហាមឃាត់ជាច្រើនបទៀត៕

*ដោយ : អរិយបុត្រ*

# តេរេសា ភឹម សុភ័ក្រ ដូនជីទីបី នៃក្រុមគ្រួសារព្រះនាងម៉ារីជាទីពឹងនឹងពំនាក់




បងស្រីតេរេសា ភឹម សុភ័ក្រ គឺជាដូនជីជនជាតិខ្មែរទី៣ហើយ ដែលបានថ្វាយខ្លួនទៅព្រះជាម្ចាស់ សម្រាប់ក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់ នៅសាលាបណ្តុះបណ្តាលវិជ្ជាជីវៈដុនបូស្កូសាលេស៊ាន(ទឹកថ្លា) កាលពីថ្ងៃទី៥ សីហា ២០១៦នេះ ដោយមានតំណាងគ្រីស្តបរិស័ទចូលរួមប្រមាណជិត២០០នាក់។ នេះជាលើកដំបូងដែលបេក្ខនារី សុភ័ក្រ បានថ្វាយពាក្យសច្ចាប្រណិធាន នៅចំពោះមុខព្រះសហគមន៍ ដែលមានបងស្រី ដេសស៊ីកា សាល់វ៉ាញ៉ា ប្រធានក្រុមគ្រួសារ ជាអ្នកទទួលពាក្យសច្ចា និងមានលោកអភិបាលព្រះសហគមន៍កាតូលិក គីគេ ហ្វីការេដូ ជាអធិបតី។

ពិធីសច្ចាប្រណិធាន បានចាប់ផ្តើមដោយពិធីបុណ្យអភិបូជា ដែលជាគ្រឹះដ៏សំខាន់នៅក្នុងព្រះសហគមន៍កាតូលិក។ ចម្រៀងលើកតម្កើងព្រះជាម្ចាស់បានបន្លឺឡើងព្រមជាមួយនឹងបេក្ខនារីហែរចូលនៅក្នុងពិធីបុណ្យ ដោយមានបងស្រីប្រធាននៃក្រុមសាមណេរនាំមុខ និងអមដោយសាច់ញាតិចូលទៅកាន់ទីសក្ការៈ(អាសនៈ)។

បងស្រីម៉ារីតាំង សុវណ្ណនៈ ជាបងស្រីជនជាតិខ្មែរដំបូង ដែលទើបតែថ្វាយពាក្យសច្ចាប្រណិធានអស់មួយជីវិត កាលពីឆ្នាំមុន បានអានជីវប្រវត្តិសង្ខេបរបស់ បងស្រីសុភ័ក្រ ដើម្បីបង្ហាញឲ្យព្រះសហគមន៍បានស្គាល់។ នៅក្នុងពិធីសច្ចាប្រណិធាន បងស្រីតេរេសា ភឹម សុភ័ក្រ ជាកូនច្បងក្នុងចំណោមបងប្អូនប្រាំនាក់ នៃគ្រួសារដែលកាន់ព្រះពុទ្ធសាសនាបានប្រកាសដោយមុតមាំថា ដាក់ខ្លួនរស់នៅទាំងស្រុងតាមព្រះបន្ទូល រួមជាមួយបងស្រីឯទៀត ដោយប្រកាសអំពីព្រះគ្រីស្តឲ្យយុវជនស្គាល់ព្រះអង្គតាមគំរូរបស់សន្តយ៉ូហានបូស្កូ និងសន្តី ម៉ារីយ៉ា ដូមីនីកា ម៉ាស្សារេឡូ ដែលជាស្ថាបនិកនៃក្រុមគ្រួសារព្រះនាងម៉ារីជាទីពឹងពំនាក់។ នៅចំពោះមុខសហគមន៍បងស្រី នៃក្រុមគ្រួសារនេះ និងអស់អ្នកដែលមានវត្តមាននៅទីនោះ បេក្ខនារី ដែលមកពីខេត្តកំពង់ធំរូបនេះ បានប្រកាសបន្តថា "សូមស្ម័គ្រចិត្តថ្វាយខ្លួនទាំងស្រុង ដោយសេរីទៅព្រះអង្គ ដោយថ្វាយពាក្យសច្ចាប្រណិធានថា នឹងរស់នៅតាមព្រហ្មចារិនី ភាពក្រីក្រ និងក្រោមពាក្យបង្គាប់អស់រយៈពេលមួយឆ្នាំក្រោមការណែនាំរបស់បងស្រី ដេសស៊ីកា សាល់វ៉ាញ៉ា ជាតំណាងរបស់អ្នកម្តាយប្រធាន ស្របតាមរបៀបនៃការរស់នៅតាមដំបូន្មានរបស់ព្រះយេស៊ូ ដែលមានចែងនៅក្នុងធម្មនុញ្ញរបស់ក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់"។ បងស្រី ដេសស៊ីកា ជាប្រធានបានទទួលពាក្យសច្ចាប្រណិធានបណ្តោះអាសន្ន របស់បេក្ខនារី ដោយប្រកាសទទួលស្វាគមន៍បងស្រី សុភ័ក្រ ក្នុងគ្រួសារបុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់ ចាប់ពីនេះតទៅ និងរស់នៅជាមួយគ្នាកាន់តែជិតស្និទ្ធ ហើយរួមគ្នាជាធ្លុងតែមួយក្នុងការតាំងចិត្តថ្វាយខ្លួនប្រកបទៅដោយសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ដើម្បីជាប្រយោជន៍ដល់យុវជន។ ក្រោយពីការទទួលស្វាគមន៍ បងស្រីថ្មីរួចមក លោកអភិបាលគីគេ បានប្រគល់ធម្មនុញ្ញ ដែលជាក្បួនច្បាប់ និងជាសញ្ញានៃសម្ពន្ធមេត្រី ដែលបងស្រីបានចងជាមួយព្រះគ្រីស្តជាស្វាមី និងឈើឆ្កាងដែលជាសញ្ញាសម្គាល់នៃសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ដើម្បីឲ្យបងស្រី អាចចូលរួមក្នុងអាថ៌កំបាំងដ៏អស្ចារ្យនៃបុណ្យចម្លង។ លោកអភិបាលបានពន្យល់បន្ថែមអំពីឈើឆ្កាង មានរូបព្រះយេស៊ូពិការជើងមួយចំហៀង ដែលប្រគល់ទៅបងស្រី សុភ័ក្រ ដោយមានប្រសាសន៍ថា យើងទាំងអស់គ្នា គឺជាព្រះកាយព្រះយេស៊ូ ដែលខ្វះជើងមួយចំហៀង គឺមានន័យថាខ្វះសេចក្តីស្រឡាញ់ និងមានមនុស្សជាច្រើនទាំងនៅក្នុងព្រះសហគមន៍ និងនៅខាងក្រៅមិនទាន់បានទទួលសេចក្តីស្រឡាញ់ពីយើង គឺមិនទាន់ទទួលធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។

លោកបន្តថា បងស្រីទទួលឈើឆ្កាងនេះ គឺទទួលបេសកកម្មដើម្បីបំពេញជើងដែលជាព្រះកាយព្រះយេស៊ូ ដើម្បីឲ្យគេបានស្គាល់ព្រះយេស៊ូដោយធម៌មេត្តាករុណារបស់ព្រះជាម្ចាស់។ នៅក្នុងធម្មទេសនា លោកអភិបាលគីកេ បានមានប្រសាសន៍ណែនាំបងស្រីថ្មី ក៏ដូចជាបព្វជិត បព្វជិតាថា កាលណាយើងគិតអំពីជីវិតអ្នកបួស

យើងត្រូវបង្កើតទំនាក់ទំនងឲ្យទូលាយជាងមុនដោយមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺត្រូវយកពេលវេលាអធិដ្ឋានអរព្រះគុណព្រះជាម្ចាស់ និងស្តាប់ព្រះសូរសៀងព្រះអង្គរហូត។ លោកអភិបាលបញ្ជាក់បន្ថែមថា ការស្តាប់សម្លេងរបស់ព្រះជាម្ចាស់ គឺត្រូវស្តាប់ដោយសុភាពរាបសារ និងចេះដាក់ខ្លួន ដោយត្រូវទំនាក់ទំនងតាមរបៀបវិជ្ជមានជានិច្ចព្រោះថាព្រះជាម្ចាស់ត្រូវការយើង ដើម្បីធ្វើកិច្ចការនានា។ លោកសង្កត់ធ្ងន់ថា ការស្តាប់នេះ ក៏ត្រូវចេះនិយាយពាក្យ "សូមទោស" ដែលនាំឲ្យយើងដាក់ខ្លួនជាមនុស្សមានបាបនៅចំពោះមុខព្រះជាម្ចាស់។ លោកអភិបាលបន្តថា នៅក្នុងជីវិតអ្នកបួសគឺត្រូវចេះសម្រុះសម្រួល គឺត្រូវចាញ់រហូតដោយទុកឲ្យព្រះជាម្ចាស់ជាអ្នកឈ្នះ។ ហើយយើងជាអ្នកបម្រើត្រូវចេះស្មោះត្រង់រហូត ជាមួយព្រះជាម្ចាស់ ជាមួយគ្រួសារ និងជាមួយអ្នកក្រីក្រ។ លោកអភិបាលបានណែនាំផងដែរដល់បងស្រីសុភ័ក្រឲ្យចេះធ្វើការពិភាក្សា និងមានទំនាក់ទំនងជាមួយបងស្រីប្រធានដែលណែនាំ ព្រោះថាសម្លេង របស់គាត់គឺជាពន្លឺនៃព្រះជាម្ចាស់។ មិនតែប៉ុណ្ណោះបងស្រីសុភ័ក្រត្រូវមានទំនាក់ទំនងឲ្យបានច្រើនជាមួយគ្រួសារទាំងអស់ និងត្រូវស្គាល់យុវជន និងអ្នកក្រីក្រឲ្យបានច្រើន។

ក្រុមគ្រួសារបុត្រីព្រះនាងម៉ារីជាទីពឹងពំនាក់ ជាក្រុមគ្រួសារបព្វជិតាកាតូលិក ដែលមានបេសកកម្មក្នុងការអប់រំកុមារ និងយុវជនដែលមានដូចជា មត្តេយ្យសិក្សា រហូតដល់វិទ្យាល័យ និងវគ្គបណ្តុះបណ្តាលសម្រាប់នារីដែលមានវត្តមាន នៅក្នុងប្រទេសកម្ពុជាតាំងពីឆ្នាំ ១៩៩២មកម៉្លេះ។ បច្ចុប្បន្នគ្រួសារនេះមានសមាជិកចំនួន ២៧នាក់ ទាំងនៅភ្នំពេញ និងខេត្តបាត់ដំបង ហើយមានយុវនារីខ្មែរមានចំណាប់អារម្មណ៍ និងកំពុងឈ្វេងយល់អំពីជីវិតជាបព្វជិតាក្នុងគ្រួសារនេះនៅប្រទេសភីលីពីន ចំនួន ៥នាក់ផងដែរ។ *ដាលីស*

# ព្រះសហគមន៍កាតូលិកក៏កំពុងតែយកចិត្តទុកដាក់នឹងបញ្ហាបរិស្ថាន និងអេកូឡូស៊ីដែរ



បរិស្ថាន និងអេកូឡូស៊ី វាសំខាន់ ហើយចំបាច់សម្រាប់ មនុស្សគ្រប់គ្នា ដូច្នេះកិច្ចការ និងសកម្មភាពទាក់ទងនឹងបរិស្ថាននិងអេកូឡូស៊ីនេះ គឺមិនចាំបាច់ និន្នាការ ឬសាសនាណានោះទេ នេះគឺជា ប្រសាសន៍លោកបូជាចារ្យ... អ្នកសម្របសម្រួលនៃកម្មវិធីអេកូឡូជីនៃអង្គការជេស្វីតកម្ពុជា។ លោកជាសកម្មជនបរិស្ថានមួយ ហើយដើម្បីឲ្យយល់ថាលោក និងព្រះសហគមន៍ចូលរួមចំណែកយ៉ាងណានៅក្នុងកិច្ចការនេះ សូមអានបទសម្ភាសន៍រវាងអ្នកនាំសារ និងលោក ខៃននីស កាព្រីអែល ឡូង។

**អ្នកនាំសារ** : នៅក្នុងនាមលោកបូជាចារ្យជាអ្នកសម្របសម្រួលកម្មវិធីផ្នែកអេកូឡូស៊ីរបស់អង្គការជេស្វីត តើមូលហេតុអ្វីបានជាក្រុមជេស្វីត ជាពិសេសលោកបូជាចារ្យផ្ទាល់ធ្វើកិច្ចការទាំងអស់ហ្នឹង?

**លោក ខៃននីស កាព្រីអែល ឡូង** : មកដល់ពេលនេះយើងមានបូជាចារ្យដែលធ្វើការនៅតាមសហគមន៍ ប៉ុន្តែក៏មានបូជាចារ្យមួយចំនួនធ្វើការនៅអង្គការដែរដោយឡែកសម្រាប់ខ្ញុំ គឺបម្រើការនៅអង្គការ។ អង្គការជេស្វីតនេះ គឺយើងមានកម្មវិធីដូចជា អប់រំអភិវឌ្ឍន៍ជនបទ និងការងារខ្លះជុំវិញសុខភាព ព្រមទាំងកិច្ចការបរិស្ថាន។ ដោយឡែកមូលហេតុដែលខ្ញុំ និងអង្គការចាប់អារម្មណ៍នឹងកម្មវិធីខាងលើ គឺដើម្បីជួយអ្នកក្រីក្រ។

**អ្នកនាំសារ** : តើកម្មវិធីរបស់លោកជួយសហគមន៍តាមគោលការណ៍យ៉ាងណា?

**លោក ខៃននីស កាព្រីអែល ឡូង** : កម្មវិធីបរិស្ថាននេះ គឺយើងបានធ្វើ កម្មវិធីដែលជួយដល់សហគមន៍ក្រីក្រ រស់នៅអាស្រ័យនឹងធនធានធម្មជាតិ។ ហើយដោយសារតែឆ្នាំនេះ ជាឆ្នាំករុណាតិគុណដែលយើងយកចិត្តទុកដាក់សម្រាប់អ្នកក្រីក្រ។ លោកអភិបាលនៃព្រះសហគមន៍ទាំងបីភូមិភាគក៏បានជំរុញឲ្យយើងយកចិត្តទុកដាក់និងកិច្ចការអភិរក្សសម្បត្តិធម្មជាតិនេះ។

**អ្នកនាំសារ** : តើសកម្មភាពអភិរក្សធម្មជាតិ និងការបំផ្លិចបំផ្លាញធនធានធម្មជាតិទាំងនេះមាន អ្វីពាក់ព័ន្ធ នឹងព្រះសហគមន៍កាតូលិក?

**លោក ខៃននីស កាព្រីអែល ឡូង** : ព្រះសហគមន៍អត់ដឹងប៉ុន្តែមនុស្ស គឺដឹងជាក់ស្តែងនៅក្នុងតំបន់ពីរដែលយើងបានធ្វើសកម្មភាព គឺទីមួយនៅព្រៃឡង់ និងតំបន់ស្ទឹងសែន នៅខេត្តកំពង់ធំ។ កន្លែងទាំងពីរនោះ គឺអត់មានសកម្មភាពជាប់នឹងគ្រីស្តបរិស័ទទេ ដោយសារតែទីនោះមិនមានព្រះវិហារ ហើយក៏អត់មានគ្រីស្តបរិស័ទ តែនៅទីនោះមានសហគមន៍មួយគឺសហគមន៍ ជនជាតិកួយ ដែលកំពុងតែធ្វើសកម្មភាពការពារព្រៃឡង់ និងសហគមន៍រស់នៅតំបន់ស្ទឹងសែន។ សម្រាប់ព្រៃឡង់ ព្រៃនេះសំខាន់ណាស់មិនមែនសម្រាប់តែសហគមន៍នៅទីនោះទេ គឺសម្រាប់ប្រជាជនកម្ពុជាទាំងមូល។ នេះជាព្រៃដែលធំ ដែលអាចមានមុខងារសំអាតទឹក ខ្យល់ និងបរិស្ថានផ្សេងៗ។ ទាក់ទងនឹងព្រៃឡង់នេះ សហគមន៍មួយទៀតដូចជា ស្ទឹងសែន ក៏មានប្រភពទឹកចេញមកពីព្រៃឡង់នេះផងដែរ។ ព្រៃទាំងនោះវាអាចសំអាតខ្យល់ អាកាសធាតុស្រូបកាបូន ជាប្រភពឱសថ និងជាមុខរបររបស់ប្រជាជន។ ដូច្នេះខ្ញុំជាពិសេស គឺអង្គការក៏ចាប់អារម្មណ៍ យកចិត្តទុកដាក់កិច្ចការនេះ។ សហគមន៍ដែលយើងជួយនៅទីនោះ គឺសហគមន៍ក្បាលខ្លាដោយពួកគេមានមុខរបរផ្ទាល់ខ្លួន ប៉ុន្តែភាគច្រើន គេលះបង់មុខរបរ គេចំណាយពេលខ្លួនពួកគេមកធ្វើការល្បាតតាមព្រៃនេះ ផ្លាស់ប្តូរគ្នា ដូច្នេះហើយយើងបានសម្រេចចិត្តជួយគេ។ ដោយឡែកនៅស្ទឹងសែនយើងមានកម្មវិធីអប់រំ កម្មវិធីដាំកូនឈើ។ល។

**អ្នកនាំសារ** : នៅពេលដែលអង្គការជេស្វីតបានជួយគេ តើព្រះសហគមន៍របស់យើងបានទទួលអ្វីពីសកម្មភាពទាំងនោះ?

**លោក ខៃននីស កាព្រីអែល ឡូង** : ប្រសិនបើយើងគ្រប់គ្នាមិនយកចិត្តទុកដាក់នោះ ព្រៃឡង់នឹងអស់ ហើយអាចនឹងអស់យូរណាស់ហើយ។ ជាក់ស្តែង នៅក្នុងមួយអាទិត្យ នៃដំណើរល្បាតរបស់ពួកគេ គឺ ពួកគេអាចឃាត់រឹបអូសម៉ាស៊ីនអារឈើបានយ៉ាងតិចណាស់ក៏ ៤គ្រឿង ហើយពេលខ្លះអាចរឹបអូសបាន១៦គ្រឿង។ អ្នកដឹងអត់ជាមួយនឹងម៉ាស៊ីនអានេះ គឺប្រើពេលតែ ៣នាទីគឺអាចបំផ្លាញដើមឈើធំមួយដើម ទោះបីជាវាមានអាយុប៉ុន្មាន មានគុណប្រយោជន៍ ដល់មនុស្សសត្វ និងរុក្ខជាតិជាពិសេស គឺអកូឡូស៊ីយ៉ាងណាក៏ដោយ។

**អ្នកនាំសារ** : នៅក្នុងសកម្មភាពទាំងនេះ តើលោកបូជាចារ្យ យល់យ៉ាងណាអំពីកិច្ចការដែលអង្គការជេស្វីតបានធ្វើនៅសហគមន៍ទាំងពីរជាពិសេស គឺកិច្ចការទាក់ទង នឹងកម្មវិធីអេកូឡូស៊ី ?

**លោក ខៃននីស កាព្រីអែល ឡូង** : ខ្ញុំយល់ថា ពួកគេនៅខ្វះចំណេះដឹង និងការអប់រំ ឲ្យទទួលស្គាល់តម្លៃ ឬសារៈសំខាន់ នៃធនធានធម្មជាតិ។ ពួកគេមិនសូវដឹង មិនសូវចេះ អំពីចំណេះដឹងនេះ។ ឧទាហរណ៍ពេលចូលព្រៃឡង់អ្នកកាប់ គឺជាអ្នកក្រីក្រ ដែលអាចត្រូវបានអ្នកមាន ជួលគេឲ្យកាប់។ ដូច្នេះនៅពេលនោះ ខ្ញុំពិតជាពិបាកចិត្តណាស់។ ចំណុចមួយទៀត គឺពួកគេអាចអត់មានសេរីភាពនៅក្នុងការចង្អុលអ្នកបំផ្លាញធនធានធម្មជាតិពិតប្រាកដ។

**អ្នកនាំសារ** : បន្ទាប់ពីបានបំពេញការងារមួយពេលកន្លងទៅនេះ តើសកម្មភាពរបស់លោកបូជាចារ្យ និងអង្គការបានលទ្ធផលអ្វីខ្លះ ?

**លោក ខៃននីស កាព្រីអែល ឡូង** : អ្វីដែលយើងបានទទួលនោះធំៗ គឺមានពីរ ទីមួយគឺ មិត្តភាព ទំនាក់ទំនង និងទំនុកចិត្ត។ យើងបានកសាងបណ្តាញការងារ និងទំនាក់ទំនងល្អ រវាងអង្គការផ្សេងៗអាជ្ញាធរសហគមន៍។ល។ ទីពីរ គឺការផ្លាស់ប្តូរការរីកចម្រើនការលូតលាស់នូវធនធានធម្មជាតិដែលយើងបានធ្វើ។ មកដល់ពេលនេះ កូនឈើដែលយើងបានដាំ ហើយវាអត់ងាប់មានដើមឈើខ្លះ មានអាយុ ១០ឆ្នាំ ហើយទោះបីជាយើងទើបតែចាប់ផ្តើមការងារនេះ បាន៣ឆ្នាំប៉ុណ្ណោះពេល គឺនៅក្នុងឆ្នាំ២០១៣ ។

**អ្នកនាំសារ** : តាំងពីចាប់ផ្តើមដាំមកដល់បច្ចុប្បន្ននេះ តើអង្គការដាំបានប៉ុន្មាន?

**លោក ខៃននីស កាព្រីអែល ឡូង** : យើងអាចដាំបានប្រមាណជាជាង ២ ម៉ឺនដើមនៅព្រៃឡង់ និងតាមព្រៃលិចទឹកជាពិសេសនៅ សហគមន៍ស្ទឹងសែន ដែលជាកន្លែងអេកូឡូស៊ី និងជាជីវមណ្ឌលមួយនៅកម្ពុជា។ ហើយថ្មីៗនេះ យើងគ្រោងជួយ បញ្ជ្រាបកម្មវិធីអប់រំ នៅស្ទឹងសែន នៅសាលាអំពីបរិស្ថានអនាម័យ។ យើងក៏កំពុងតរិះគិតអំពីកម្មវិធីស្រាវជ្រាវអំពី គុណភាពទឹកផងដែរ ។

**អ្នកនាំសារ** : តើលោកបូជាចារ្យមានមានគោលដៅធ្វើអ្វីបន្តទៀតទេនៅថ្ងៃខាងមុខនេះ?

**លោក ខៃននីស កាព្រីអែល ឡូង** : គោលដៅទីមួយ គឺយើងចង់ស្តារប្រព័ន្ធអេកូឡូស៊ីឡើងវិញ ដោយយើងយកចិត្តទុកដាក់នៅតំបន់ដែលសំខាន់ដូចជា នៅព្រៃឡង់ ឬទន្លេ និងពង្រីកពង្រឹងតំបន់នៅទីនោះ។ ទីពីរ គឺអប់រំនិងការតស៊ូមតិដើម្បីអប់រំកូនសិស្ស និងព្រះសហគមន៍ដើម្បីបង្រៀនក្មេងៗអំពីតម្លៃ និងតួនាទីរបស់ពួកគេនិងរបស់យើង។ ការងារស្រាវជ្រាវ និងបោះពុម្ពផ្សាយដោយយើងចង់ធ្វើផែនទី ព្រៃនៅកំពង់ធំ។ ទីបួន គឺបន្តឲ្យមាននិរន្តភាព នៃការងាររបស់យើង មួយទៀត យើងមានកម្មវិធីកាត់បន្ថយប្លាស្ទិកសម្រាប់ បូជាចារ្យជាដើម ។

*ដោយ : ដាលីស*

# រឿងថៅកែរេចបង្ហិច ជាក្តីកង្វល់សម្រាប់បណ្តាកម្មករនិងកម្មការនីនៅកម្ពុជា



រូបថតពីហ្វេសបុក

ការរេចបង្ហិចរត់ចោលកម្មករ របស់ថៅកែរោងចក្រ គឺជាក្តីកង្វល់មួយ របស់បងប្អូនកម្មករ និងកម្មការិនីដែលកំពុងតែបម្រើការនៅក្នុងវិស័យឧស្សាហកម្មកាត់ដេរនៅពេលបច្ចុប្បន្ននេះ។

អង្គុយនៅក្រោមឆ័ត្រក្រោមកំដៅថ្ងៃដើម្បីទទួលទានអាហារថ្ងៃត្រង់នៅមុំផ្លូវវេងស្រេង ទា ស្រីអូន ដែលជាកម្មការិនីរោងចក្រកាត់ដេរមួយនៅសួនឧស្សាហ-កម្មកាណាឌីយ៉ា បានសម្តែង ការព្រួយបារម្ភថា ធ្វើការរាល់ថ្ងៃនាងចេះតែមានអារម្មណ៍ថា ភ័យរឿងថៅកែវិចបង្ហិចដោយសារតែរឿងនេះ នាងឧស្សាហ៍ឮព័ត៌មានគេផ្សាយជាបន្តបន្ទាប់។

ស្រីអូន បានឲ្យដឹងថា បើធ្វើការអត់បានលុយ ហើយថៅកែរត់ចោល អត់មានដំណោះស្រាយបែបនេះ ស្លាប់កម្មករអស់ហើយ។ ស្រីអូនបានដាក់ចម្ងល់ងាយៗតាមការយល់ដឹងរបស់នាងថា "ខ្ញុំមិនយល់ ហេតុអី អាជ្ញាធរឲ្យថៅកែអស់ហ្នឹងរត់ស្រួលៗ យ៉ាងនេះ។

កញ្ញាសាញ់ សុជាតា ដែលជាកម្មការិនីរោងចក្រ ដែលកំពុងតែស្រស់ ស្រូបអាហារថ្ងៃត្រង់នៅម្តុំនោះដែរ បានបន្លឺសំដីរបស់នាងថា ធ្វើការមួយខែ បានលុយតែបន្តិចបន្តួច ហើយថៅកែ នៅរត់ទៀតឲ្យពួកនាងទៅរំពឹងអី អាជ្ញាធរហេតុម៉េចក៏នៅសម្ងំស្ងៀមទៀត ។

កញ្ញាបានបញ្ជាក់ថា "ម្នាក់ៗធ្វើការចង់បានលុយ ខ្លះថែមម៉ោងឡើងក្រិនចង្កេះតែដល់ខែ បើកលុយ អាជ្ញាធរបណ្តោយឲ្យថៅកែរត់ចោលកម្មករស្រួលៗ មានអារម្មណ៍ឯណាទៅធ្វើការ"។ កញ្ញាបានបញ្ជាក់ទៀតថា "ឮព័ត៌មាននេះ អស់អារម្មណ៍ធ្វើការតែម្តង។ ប្រាក់ខែកំពុងតែតិចផង ដល់ទៅមានព័ត៌មានថៅកែរត់ចោលទៀត ខ្ញុំទន់ដៃទន់ជើងតែម្តង"។

មិនមែនតែស្រីអូន និង សុជាតា ទេដែលបារម្ភ លោក ឈិន ច័ន្ទសុផា ជា អ្នករត់ម៉ូតូឌុប កំពុងតែអង្គុយចាំទទួលកូនស្រីចេញទៅបាយថ្ងៃត្រង់នៅផ្ទះជួល ម្តុំផ្លូវវេងស្រេងនេះ ក៏បានបង្ហាញនូវក្តីបារម្ភជុំវិញ ករណីនេះដែរ។

សុផា បានឲ្យដឹងថា ដេរថែមម៉ោង ផងអីផង សរុបទៅ កូនរបស់លោកម្នាក់ៗអាចនឹងបើកប្រាក់ខែមកបានម្នាក់ ជិត ២០០ដុល្លារ អីដែរសរុបទៅ បីនាក់ ដូច្នេះអាចបានជាង ៥០០ដុល្លារទៅ ជិត ៦០០ ដុល្លារ នៅក្នុងមួយ ខែ គ្រាន់នឹងដោះស្រាយជីវភាពចុះបើថៅកែ ដល់ពេលបើកប្រាក់ខែរត់បាត់មិនយ៉ាប់។

លោក សុផា បានដាក់សំណួរ ថា "ខ្ញុំមិនយល់ តាមស្តាប់ព័ត៌មាន ថៅកែរេចបង្ហិចនោះវាស្រួលពេកតែម្តង អាជ្ញាធរមិនដឹងធ្វើអី"។

គិតត្រឹមខែកក្កដា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានឲ្យដឹងថា នៅទូទាំងប្រទេសកម្ពុជាមាន សហគ្រាសគ្រឹះស្ថានសរុបមានចំនួន ៦.៧៤២ សហគ្រាស រួមមាន រោងចក្រកាត់ដេរ និងផលិតស្បែកជើង១.០២៧ និងមានកម្មករនិយោជិតបម្រើការងារ ចំនួន ១.១១៨.១៧៥នាក់ សហគ្រាសគ្រឹះស្ថានបើកថ្មីមានចំនួន ៥៧ ក្នុងនោះរោងចក្រកាត់ដេរ និងផលិតស្បែកជើងចំនួន២០។

ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយរហូតមកដល់ពេលនេះ ព័ត៌មានដែលចុះផ្សាយថា ថៅកែរេចបង្ហិចរត់ចោលរោងចក្រ និងកម្មករ ក៏មានជាហូរហែរដែរ។

ជាក់ស្តែង បងប្អូនកម្មករនិងកម្មការិនីរាងចក្រកាត់ដេរសម្លៀកបំពាក់មួយកន្លែងឈ្មោះ ដុង ហ្វៃ នីតវៀរ អេហ្វធីវ៉ាយ នៅម្តុំចាក់អង្រែក្រោម ខណ្ឌមានជ័យ គឺកំពុងតែជួបប្រទះនូវបញ្ហានេះ។

កាលពីដើមខែ សីហា ឆ្នាំ២០១៦ នេះពួកគេប្រមាណជា ជាង ១០០ នាក់ បាននាំគ្នា ជួបជុំគ្នាមួយ នៅមុខរោងចក្រ ដើម្បី ស្វែងរកអន្តរាគមន៍ ពីប្រមុខរដ្ឋាភិបាលកម្ពុជាពីអាជ្ញាធរ ដើម្បីទាមទារ ប្រាក់ខែ និងប្រាក់អតីតភាពការងាររបស់ពួកគេ។

ដើម្បីទាមទារដោះស្រាយបញ្ហានេះ ពួកគេបានធ្វើការជួបជុំគ្នា ទាមទារការដោះស្រាយជាបន្តបន្ទាប់ប៉ុន្តែ នៅមិនទាន់មានដំណោះស្រាយឡើយ ។

ពួកគេបានអះអាងថា ថៅកែរោងចក្រដុងហ្វៃ នីតវៀរ អេហ្វ.ធី.វ៉ាយ បានរត់ចោលពួកគេដោយគ្មានដំណោះស្រាយបែបនេះប្រមាណជា ២ ខែ រួចមកហើយ ដោយឡែកអាជ្ញាធរវិញ គឺបានត្រឹមតែចុះមកពន្យល់ពីនីតិវិធីច្បាប់ ប៉ុន្តែមិនបានចាត់ការដោះស្រាយ ជូនពួកគេឡើយមកដល់ពេលបច្ចុប្បន្ននេះ។

បទពិសោធន៍នេះ ស្រីអូន បានអះអាងថា នេះគឺជាក្តីបារម្ភមួយ ដោយសារតែពេលនេះ ក្រៅពីប្រាក់ខែស្រីអូន ក៏រំពឹងទៅលើប្រាក់អតីតភាពការងារនៅទីនោះដែរ ដោយសារតែស្រីអូនក៏បានធ្វើការងារនៅរោងចក្រ ដែលស្រីអូនបានធ្វើនេះប្រហែលជាជិត៥ ទៅ៦ឆ្នាំដែរហើយ។

បើតាមស្រីអូន ក្រៅពីប្រាក់អតីតភាពការងារកញ្ញាដែលជាកម្មការិនី និងបងប្អូនកម្មការនី និងកម្មករនៅក្នុងរោងចក្រមួយចំនួន នៅមានលេងតុងទីន ថែមទៀតផង។

ស្រីអូនបានបន្តថា សម្រាប់ការលេងតុងទីននេះ គឺនាង លេង ៣ក្បាល ដែរ ដោយមួយក្បាល ២០ដុល្លារ ដែលពេលកើបទៅ សង្ឃឹមថា នឹងអាចប្រមូលបាន ៤.០០០ទៅ ៥.០០០ ដុល្លារ ដោយសារលេងគ្នាច្រើន ។

ស្រីអូន បានបញ្ជាក់ថា មិនដឹងធ្វើម៉េចទេ ហ៊ឹ! មានតែបន់ព្រះហើយ។

ស្រីអូនបានបន្តទៀតថា កន្លងមកមិនមែនតែរូបនាងទេ កម្មករ និងកម្មការិនីជាច្រើននាក់ទៀតដែលកំពុងតែជួយគ្នាតាមរូបភាពនេះ ដូច្នេះនេះមិនមែនជាបញ្ហាកង្វល់របស់នាងតែម្នាក់នោះឡើយ។

កម្មការនីរោងចក្រកាត់ដេររូបនេះបានអះអាងថា ពួកយើងមានប្រាក់ខែតិច ដូច្នេះដើម្បីសន្សំលុយ បានគឺមានតែធ្វើតាមរយៈរូបភាពទាំងនេះតែប៉ុណ្ណោះ។

*ដោយ អរិយបុត្រ*

# ក្រសួងទេសចរណ៍ប្រកាសកំណត់ម៉ែត្រឲ្យអ្នកជក់បារី

កាលពីថ្ងៃទី២៣ ខែ សីហា ក្រសួងទេសចរណ៍បានប្រកាសតម្រូវអ្នកជក់បារីត្រូវដើរចេញចម្ងាយ ៥ម៉ែត្រ ពីទីតាំងទេសចរណ៍ ភោជនីយដ្ឋាន អាហារដ្ឋាន និងសណ្ឋាគារ ដើម្បីកាត់បន្ថយផលប៉ះពាល់ ពីការបង្ហុយផ្សែងបារី ដល់ភ្ញៀវទេសចរ។

នេះគឺជាសារមួយ ដែលលោក ហោ សារុន អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ បានថ្លែងក្នុងពិធីបើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបរិស្ថានគ្មានផ្សែងបារីដល់មន្ត្រីអធិការកិច្ច ទេសចរណ៍ ។

លោកបានបញ្ជាក់ថា ក្រសួងសុខាភិបាល និងក្រសួងទេសចរណ៍ នឹងរៀបចំក្រុមអធិការកិច្ច ចុះផាកពិន័យចំពោះម្ចាស់ភោជនីយដ្ឋាន សណ្ឋាគារ ឬមូលដ្ឋានសេវាកម្មទេសចរណ៍ណា មិនគោរពការណែនាំ ដែលតម្រូវឱ្យអ្នកជក់បារីត្រូវដើរចេញ ចំងាយ៥ម៉ែត្រ ពីភោជនីយដ្ឋាន ឬទីតាំងសេវាកម្មទេសចរណ៍ផ្សេងៗ។

លោកបានថ្លែងទៀត ការអនុវត្តការផាកពិន័យនេះ ធ្វើឡើងស្របតាមអនុក្រឹត្យស្តីពីវិធានការហាមជក់ ឬការបង្ហុញផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការ ឬកន្លែងសាធារណៈ ដែលនឹងចូលជាធរមានចាប់ពីថ្ងៃទី១៦ កញ្ញា ២០១៦ខាងមុខ។ លោកបានបន្តទៀតថា ការបើកវគ្គបណ្តុះបណ្តាល ស្តីពីការអនុវត្តបរិស្ថានគ្មានផ្សែងបារី ដល់មន្ត្រីអធិការកិច្ចទេសចរណ៍នៅតាមបណ្តាខេត្ត រាជធានីនេះ គឺធ្វើឡើងដើម្បីជំរុញឱ្យមានការអនុវត្តការណែនាំ និងអនុក្រឹត្យនៅតាមតំបន់ទេសចរណ៍នៅគ្រប់រាជធានី ខេត្តទូទាំងប្រទេស។

លោកបានថ្លែងបញ្ជាក់ថា ម្ចាស់អាជីវកម្មទេសចរណ៍ត្រូវចូលរួមទប់ស្កាត់បញ្ហានេះ ហើយនៅក្នុងករណីមិនអនុវត្តន៍តាមការណែនាំរបស់ក្រសួងនោះទេ គឺក្រសួងនឹងមិនផ្តល់ ឬបន្តអាជ្ញាប័ណ្ណអាជីវកម្មទេសចរណ៍ដល់ម្ចាស់អាជីវកម្មណាដែលបំពាននោះឡើយ។

# ប្រធានាធិបតីកូរ៉េខាងត្បូងមកបំពេញទស្សនកិច្ចនៅកម្ពុជានៅខែតុលា

សម្តេចតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជាបានមានប្រសាសន៍ថា លោកស្រី ផាក ជឺនហ៊ី (Park Geun-hye) ប្រធានាធិបតីកូរ៉េខាងត្បូងនឹងមកបំពេញទស្សនកិច្ចនៅកម្ពុជានៅក្នុងឆ្នាំនេះ។

សម្តេចតេជោ ហ៊ុន សែន បានថ្លែងដោយខ្លី បង្ហើបអំពីគម្រោងទស្សនកិច្ចរបស់លោកស្រី ប្រធានាធិតី កូរ៉េខាងត្បូងបែបនេះ នៅក្នុងពេលសម្តេចអញ្ជើញចូលរួមជាអធិបតីភាពនៅក្នុងវេទិកាស្តីអំពីការការពារ និងអភិរក្ស ធនធានធម្មជាតិ កាលពីថ្ងៃទី២២ ខែសីហា ថ្មីៗនេះ។

សម្តេចតេជោ ហ៊ុន សែន បានមានប្រសាសន៍ថា លោកស្រី ផាក ជឺនហ៊ី នឹងមកបំពេញទស្សនកិច្ច នៅកម្ពុជានៅខែតុលា។

គួររំលឹកថា កម្ពុជា និងប្រទេសកូរ៉េខាងត្បូង គឺបានភ្ជាប់ទំនាក់ទំនងការទូតនឹងគ្នានៅក្នុងឆ្នាំ១៩៩៧ ហើយចាប់តាំងពីពេលនោះមក ប្រមុខដឹកនាំនៃប្រទេសទាំងពីរបានផ្លាស់ប្តូរដំណើរបំពេញទស្សនកិច្ចទៅវិញទៅមកជាបន្តបន្ទាប់។

វត្តមានលោកស្រីនៅក្នុងខែតុលានេះ នឹងក្លាយជាប្រធានាធិបតីចុងក្រោយបីរូបនៃប្រទេសកូរ៉េខាងត្បូង ដែលបានមកបំពេញទស្សនកិច្ចនៅកម្ពុជា បន្ទាប់ពីលោក រ៉ូ មូ យន់ ដែលបានមកបំពេញទស្សនកិច្ចនៅខែវិច្ឆិកា ឆ្នាំ២០០៦ និងលោក លី មីញ៉ុងបាក នៅខែដដែលប៉ុន្តែឆ្នាំ២០១២។

ដោយឡែកសម្តេចតេជោ ហ៊ុន សែន នៅក្នុងនាមជាប្រមុខរដ្ឋាភិបាលកម្ពុជាក៏បានចេញទៅបំពេញ ទស្សនកិច្ចនៅប្រទេសកូរ៉េខាងត្បូង ជាច្រើនដងដែរ ។

# សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបង្ហាញនូវព័ត៌មានរន្ធត់ជាថ្មីចំពោះការវាយប្រហារនៅប្រទេសតួកគី

ទីភ្នាក់ងារពត៌មានកាតូលិក បានអះអាងថា សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានរៀបចំនូវពិធីថ្វាយអភិបូជាភ្លាម ដើម្បីអធិដ្ឋាននិងសំដែងនូវការចូលរួមរំលែកទុកដល់ជនរងគ្រោះដែលបាន ស្លាប់ និងរបួសនៅក្នុងហេតុការនៃការវាយប្រហារដ៏រន្ធតនៅក្នុងពិធីរៀបការមួយ។

ការវាយប្រហារនេះបានកើតមានឡើងកាលពីថ្ងៃទី២០ ខែសីហា ដោយបានសម្លាប់មនុស្ស អស់ចំនួន ៥០រូប និងរបួសជាង ១០០ នាក់។

សម្តេចប៉ាប ហ្វ្រង់ស៊ីស្កូបានថ្លែងថា បងប្រុសបងស្រី បូជាចារ្យ និងគ្រិស្តបរិស័ទទាំងអស់ ព្រឹត្តិការណ៍ដែលកើតឡើងនៅតួកគីនៅថ្ងៃទី២០ ខែសីហា គឺជាព្រឹត្តិការណ៍ដ៏រន្ធត់បំផុត ហើយបានប្រកាសការអធិដ្ឋានដល់ជនរងគ្រោះ ទាំងអ្នកស្លាប់ និងរបួសជាពិសេសគឺទៅដល់ក្រុមគ្រួសាររបស់ពួកគេ ។

ព្រឹត្តិការណ៍នៃការវាយប្រហារនេះ គឺបានកើតមានឡើងដោយសារតែការវាយប្រហារមួយ ដែល គឺជឿថា ជាការវាយប្រហារអត្តឃាត ដោយវាមានកើតមានឡើង នៅម៉ោងប្រមាណជា ១១ យប់ នៅខេត្តហ្គាសានទេប នៅភាគខាងត្បូងប្រទេសតួកគី ជាប់នឹងព្រំដែន ស៊ីរី ។

# ពិធីសម្ពោធជួងនៅបឹងទំពុន

ព្រះវិហាព្រះកុមារយេស៊ូបឹងទំពុនបានប្រារព្ធពិធីសម្ពោធជួង កាលពីថ្ងៃអាទិត្យទី១១ កញ្ញា ២០១៦កន្លងទៅក្រោមអធិបតីភាពរបស់លោកអភិបាលអូលីវីយ ជ្មីតអ៊ីស្លែរ ជាអភិបាលប្រចាំព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ រួម និងគ្រីស្តបរិស័ទជាតិនិងអន្តរជាតិប្រមាណជា២០០នាក់។

ជួងថ្មីទាំងពីរនោះ គឺត្រូវបានព្រះសហគមន៍បឹងទំពុនប្រសិទ្ធនាមថា ជួងសន្តគ្រីស្តទូតយ៉ាកុប និងសន្តីវីតានៅភូមិការសៀរ។

មុនពេលថ្វាយអភិបូជាលោកអភិបាលអូលីវីយេបានអធិដ្ឋាននៅខាងមុខជួងនេះ ដោយពោលថា "យើងខ្ញុំសូមទូលអង្វរព្រះអង្គសូមប្រោសប្រទានឲ្យអស់អ្នដែលឮសម្លេងជួងនេះអាចរត់ទៅជួបជុំគ្នាក្នុងព្រះវិហារដោយរីករាយផង"។

ក្រោយពីពិធីប្រិសិទ្ធពរលើជួងនិងពិធីកាត់ខ្សែបូររួចលោកអភិបាលអូលីវីយេបានបន្លឺសម្លេងជួងនេះចំនួន ៣ដងដើម្បីបញ្ជាក់ថា ជួងថ្មីនេះបានដាក់ឲ្យប្រើប្រាស់ជាផ្លូវការណ៍តាមតម្រូវការរបស់ព្រះសហគមន៍បឹងទំពុនចាប់ពីពេលនោះតទៅ។



ក្នុងធម្មទេសនាលោកអភិបាលភូមិភាគភ្នំពេញរូបនេះបានមានប្រសាសន៍ថា នេះជាពេលវេលាដែលយើងទាំងអស់គ្នាលើកតម្កើង និងកោតសសើរព្រះជាម្ចាស់។ លោកបន្តថា "ហេតុអ្វីយើងត្រូវលើកតម្កើងព្រះជាម្ចាស់? ព្រោះតែទ្រង់បានរំដោះមនុស្សគ្រប់រូបឲ្យរួចពីអំពើបាប។ តែស្របពេលនោះព្រះអង្គកបានអញ្ជើញគេឲ្យកែប្រែចិត្តគំនិត ហើយការកែប្រែចិត្តគំនិតនេះមិនមែនធ្វើដោយកម្លាំងយើងនោះទេ គឺយើងត្រូវពឹងផ្អែកទៅលើព្រះវិញ្ញាណដ៏វិសុទ្ធ"។ លោកអភិបាលបន្ថែមថា ព្រះជាម្ចាស់មានព្រះហឫទ័យស្មោះត្រង់ចំពោះយើង ហើយតាមរយៈភាពស្មោះត្រង់នេះ បានណែនាំឲ្យយើងកែប្រែចិត្តគំនិតដូចសន្តសិលាកាលពីដើម។

ក្នុងឱកាសពិធីសម្ពោទជួងថ្មីនោះ លោកអភិបាលអូលីវីយេ ក៏បានធ្វើអគ្គសញ្ញាលាបថ្វាសជូនដល់បេក្ខជនចំនួន២៧នាក់ផងដែរ។

*ដោយ ស្រីម៉ាច*

# សេដ្ឋកិច្ចហាក់រីកចម្រើន តែពលរដ្ឋនៅតែ



ផលិតផលជជុះនៅស្រុកខ្មែរកាលពីអំឡុង ជាងពីទសវត្សរ៍មុន គឺល្បីល្បាញតែត្រឹមសម្លៀកបំពាក់ទេ ប៉ុន្តែនៅពេលបច្ចុប្បន្ននេះមានគ្រប់យ៉ាង ហើយសូម្បីតែហាងលក់ទំនិញជជុះនេះក៏មានយីហោរមានក្រុមហ៊ុននាំចូលត្រឹមត្រូវថែមទៀត ខណៈសេដ្ឋកិច្ច ហាក់ដូចជា មាននិន្នាការប្រសើរក៏ដោយ។

ដោយសារតែស្រុកខ្វះខាត នៅចុងសម័យនៃសង្គ្រាមស៊ីវិល ផលិតផលជជុះបានចាប់ផ្តើមហូរចូលមក សង្គមកម្ពុជានៅក្នុងអំឡុងនៃទសវត្សរ៍នៃឆ្នាំ១៩៩០ ប៉ុន្តែទំនិញជជុះនៅសម័យនោះ គឺសំបូរបំផុតត្រឹមតែជាសម្លៀកបំពាក់ ក្រោយមក ក៏មានម៉ូតូ និងរថយន្ត ប៉ុន្តែសម័យនេះ គឺសឹងតែគ្រប់យ៉ាងរាប់តាំងពី តុ ទូ កែវ ចាន ស្លាបព្រា របស់អេឡិចត្រូនិចរហូតដល់សម្ភារឧបករណ៍ពេទ្យ ថែមទៀតផង ។

លោក ទេព សិទ្ធិ ជាប្រជាពលរដ្ឋកម្ពុជាមួយរូប បានមានប្រសាសន៍ថាគ្មាននរណាចង់ប្រើរបស់ជជុះទេប៉ុន្តែវាទាក់ទងនឹងជីវភាព ។

លោក សិទ្ធិ បានបញ្ជាក់ថា "ដើរសួរទៅមើល! តើមាននរណាចង់ប្រើរបស់ជជុះ បើខ្លួនមានលទ្ធភាពមានសេដ្ឋកិច្ចនិយាយឲ្យចំទៅគឺលុយ តែយើងប្រើ គឺដោយសារតែយើងវាអត់"។

លោកបានបន្តថា អ្នកខ្លះគេហៅរបស់ជជុះថា សុទ្ធតែជាសំរាម ប៉ុន្តែបើវាអត់ជួនកាលអាសំរាម នេះក៏វាមានប្រយោជន៍ដែរ មិនមែនអត់តម្លៃទាំងអស់នោះទេ។

លោកឃិត សុបញ្ញា ដែលជាមន្ត្រីអង្គការសង្គមស៊ីវិលមួយរូបបានប្រាប់អ្នកនាំសារថា នៅយើងនៅមានអ្នកដែលក្រីក្រច្រើន ដូច្នេះហើយបានជាផលិតផលជជុះ ដែលនៅមានតម្លៃប្រើប្រាស់ត្រូវបានគេនាំចូលយកមកបំពេញសេចក្តីត្រូវការ។

លោកបានបន្តចែករំលែកថា កាលពីដើមទសវត្សរ៍នៃឆ្នាំ១៩៩០ ស្រុកយើងវាអត់មែនទែន ឃើញអត់ម្នាក់ៗ ដណ្តើមគ្នាទិញ ខោអាវជជុះ ចាក់គរ តែដល់ពេលដែលជីវភាពរាងប្រសើរបន្តិច អាសម្លៀកបំពាក់ជជុះដដែលនេះ ត្រូវគេរើសទៅបោក ហើយអ៊ុត ដាក់ព្យួរ ហើយឥឡូវនេះ មានកន្លែងខ្លះឡើងដល់ហាងរៀបចំតុបតែងយ៉ាងស្អាត មានកន្លែងសម្រាប់លក់មានកញ្ចក់ឆ្លុះមើលម៉ាអេមប៉ុន្តែនៅតែជជុះដដែលទេ ។

លោកបានបញ្ជាក់ថា "ពីមុនវាអត់ ក៏ចេះទៅរើសនឹងគេទៅ ខ្លះ៥០០រៀល ខ្លះ ១.០០០រៀល អីក៏ចេះតែស្លៀកបិតបាំងរាងកាយទៅ តែពេលនេះ ចង់បានប្រេន (Brand ឬ យីហោ)នឹងគេក៏នៅតែពាក់អាជជុះដដែល ប៉ុន្តែ គ្រាន់តែដើរទិញតាមហាង ដោយតម្លៃខ្លះ ៥ដុល្លារខ្លះ ១០ដុល្លារគ្រាន់ពាក់ដែរ"។

លោកបានបញ្ជាក់បន្តទៀតថា "ខោអាវប្រេនគេ ១០០ដុល្លារទៅ ២០០ ដុល្លារឯណោះ តែប្រេនយើង ៥ ទៅ១០ ដុល្លារ មានទៅខុសគ្នាខ្លាំងអី យើងអាចបន្លំៗបានតើ"។

លោកបានបន្តទៀតថា នរណាក៏ដឹងថា របស់ជជុះវាអាចជាសំរាមនៅស្រុកគេមែន ប៉ុន្តែ យើងក៏មិនអាចបដិសេធវាបានដែរ នៅក្នុងកាលៈទេសៈនាពេលបច្ចុប្បន្ន។ ដោយសារតែប្រទេសយើងនៅមាន អ្នកដែលក្រីក្រច្រើន ខណៈដែលជីវភាព និងតម្រូវការនៃការចង់បានរបស់របរប្រើប្រាស់ដូចជាគេ ដូចជាឯងដែរនោះ។

ជុំវិញបញ្ហាជីវភាពនេះ លោក ទេព សិទ្ធិ បានមានមានប្រសាសន៍បន្ថែមថា កម្រិតជីវភាពរបស់លោក និងប្រជាពលរដ្ឋនៅក្នុងប្រទេស គឺពិតជាមានការរីកចម្រើនមែន បើប្រៀបធៀបនឹង កាលពីជាង២ទសវត្សរ៍មុន ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ពលរដ្ឋកម្ពុជាជាច្រើន ដោយរួមទាំងលោកផងដែរ ពិបាកនឹងគេចឲ្យផុតពីរបស់ជជុះនេះណាស់។

លោកបានបន្តទៀតថា ពីមុនប្រាក់ខែត្រឹមតែបួនទៅដប់ម៉ឺនទេ ហើយពេលនេះប្រាក់ខែ មន្ត្រីរាជការ កម្មករ ហោចណាស់ក៏ប្រមាណជា ១៥០ដុល្លារ ឬ៦០០,០០០ ប៉ុន្តែតម្លៃទំនិញ ក៏វាឡើងទៅតាមនោះដែរ ដូច្នេះបើចង់ឲ្យលោកឬឲ្យអ្នកដទៃមិនប្រើរបស់ជជុះនេះ គឺមិនអាចទៅរួចទេ។

លោកបានបញ្ជាក់ថា "ដូចជាទូរទស្សន៍ ម៉ូតូអីនេះ បើថ្មីវិញទាល់តែកាន់លុយទាំងខ្ទាស់យកទៅទិញ តែសម្រាប់យើងអត់ ទូរទស្សន៍ ២០ ទៅ៣០ ដុល្លារអាចមើលបាន ហើយអាម៉ូតូ ៦០០ទៅ ១.០០០ ដុល្លារអីបានមានលទ្ធភាព គ្រាន់តែវាជារបស់ជជុះប៉ុណ្ណោះ"។

លោក ជេញ ហេងរតនា ជាអាជីវករមួយរូប បានចូលរួមបញ្ចេញយោបល់ជុំវិញ បញ្ហាទំនិញជជុះនៅស្រុកខ្មែរនេះផងដែរថា របស់ជជុះឥឡូវនេះចង់ស្ទើរក៏មានដែរ ហើយអ្នកមានខ្លះ ក៏នៅមិនទាន់ អាចជៀសផុតទាំងស្រុងពីរបស់ជជុះនេះនៅឡើយទេ ។

លោកបានបន្តថា ជាធម្មតាទេ របស់ជជុះវាជាសំរាម ដោយសារតែនៅស្រុកគេ គេលែងត្រូវការ តែយើងនៅស្រុកយើងនៅមានតម្លៃ ឥចឹងវានៅមានតម្លៃ មានទីផ្សារ ដូច្នេះឈ្មួញ ត្រូវតែនាំចូល ។

លោកបានបញ្ជាក់ថា "វាជារបស់សំរាមមលុះត្រាតែយើងមិនត្រូវការតែបើយើងនៅតែត្រូវការ វានៅតែជាទំនិញ វានៅតែជាមាសប្រាក់របស់គេឥចឹង"។

លោកបានបន្តទៀតថា ជារួមមកនៅក្នុងកាលៈទេសៈនេះ របស់ឬ ទំនិញជជុះវានៅមានតម្លៃនៅកម្ពុជា នៅឡើយ ហើយប្រជាពលរដ្ឋកម្ពុជា រួមទាំងលោកគឺពិបាកនឹងកាត់ផ្តាច់ពីរបស់ជជុះណាស់ បើមិនរបស់នេះ គឺរបស់នោះ យ៉ាងហោចណាស់ក៏មាន ខោខ្លី ឬមួយចំណែកណាមួយ ដែលជាទំនិញជជុះដែរ ។

លោកបានបញ្ជាក់ថា "ដូចខ្ញុំឥចឹងថា ឈប់ប្រើរបស់ជជុះហើយ តែ ថ្ងៃមុន

# តប្រើរបស់ជជុះ



ថតដោយ កញ្ញា

មិនដឹងជាយ៉ាងម៉េច យាយវា(ភរិយាលោក) ដើរផ្សារ ទៅរើសបានខោអាវហាត់ប្រាណមួយកំប្លេរ ដូចជាទំនងក៏ពាក់ ដល់ឥឡូវនេះទៅ"។

លោកបានរៀបរាប់ទៀតថា ដូចជាកង់របស់លោកក៏ជជុះដែរ ហើយតម្លៃវិញ គឺត្រឹមតែ ៨០ ដុល្លារទេ ខណៈដែលកង់ថ្មីវិញ បើមិនកាន់លុយ ពី១៥០ ដុល្លារឡើងទេ មិនអាចទិញជាក់ហាត់ប្រាណបានទេ ហើយកង់ថ្មីខ្លះ តម្លៃដល់ម៉ឺនដុល្លារក៏មានដែរ ។

ដោយសារតែបញ្ហាជីវភាពស្ថានភាពសេដ្ឋកិច្ច ក៏ដូចជាតម្រូវការនេះនៅកម្ពុជាមានហាងលក់សម្ភារជជុះមួយចំនួន បានឈាន ចេញពីការលក់ជាលក្ខណៈ តូចតាច ហើយបានអភិវឌ្ឍន៍ជា ប្រព័ន្ធដែលមានឈ្មោះត្រឹមត្រូវ មានសាខាជាច្រើនផងដែរ។

នៅក្នុង ចំណោមបណ្ដាហាងលក់ទំនិញជជុះទាំងនេះ សាគូ៉រា ត្រូវបានគេដឹងថា គឺជាយីហោហាង លក់ទំនិញជជុះដែលបានពង្រីកជាបន្តបន្ទាប់ហើយរហូតមកដល់ពេលនេះ បើតាមបុគ្គលិកមួយរូបនៅក្នុងហាងនេះ បានរៀបរាប់ថា ហាងទំនិញ មួយនេះមានសាខាប្រមាណជា ១៤កន្លែង ដោយមានសាខានៅតាមខេត្តមួយចំនួនថែមទៀតផងដូចជា កណ្ដាល សៀមរាប បាត់ដំបង កំពង់ស្ពឺ និងកំពង់ចាមជាដើម។

ស្ត្រីជាបុគ្គលិកហាងសាគូ៉រា មួយរូបបានឲ្យដឹងថា សាគូ៉រា ជាហាងទំនិញមួយដែលកំពុងតែលក់សម្ភារ ជាច្រើនប្រភេទជាពិសេស គឺឧបករណ៍ដែលប្រើប្រាស់ប្រចាំថ្ងៃ របស់ប្រជាពលរដ្ឋគ្រប់វ័យ គ្រប់ប្រភេទ គ្រប់ស្រទាប់ ជាពិសេស គឺវណ្ណៈកណ្ដាល។ ផលិតផលនៅក្នុងហាងនេះជាផលិតផលដែលប្រើប្រាស់រួចហើយ ប៉ុន្តែវានៅតែមានគុណភាពប្រើប្រាស់នៅឡើយ ។

ប្រភពដដែលបានបន្តថា ទំនិញនៅហាងនេះ ពេញនិយមណាស់ ហើយឥឡូវនេះ បានពង្រីកសាខា ជាច្រើន ក្រោយពេលដែលហាងនេះ បានចាប់ដៃវិនិយោគបើកដោយពាណិជ្ជករជនជាតិជប៉ុន និងជនជាតិខ្មែរ រួមគ្នាបង្កើតឡើង កាលពីជាង ១០ឆ្នាំមុន ។

កញ្ញា បានបន្តថា "សាគូ៉រា មានទំនិញរាប់សិបមុខ ប៉ុន្តែទំនិញដែលដាច់ខ្លាំង ហើយពេញនិយមសម្រាប់អតិថិជននោះគឺ មានសម្លៀកបំពាក់ ឧបករណ៍ផ្ទះបាយ ស្បែកជើង និងប្រដាប់ប្រដាក្មេងលេង ជាដើម ។

កញ្ញា បានបន្តទៀតថា នៅក្នុងហាងទំនិញសាគូ៉រា គឺបានបែងចែក និង រៀបចំមានលក្ខណៈដូចជា ហាងទំនិញលក់រាយស្តង់ដាអន្តរជាតិមួយ ដែលមានរៀបចំទំនិញនេះចែកជាច្រើនផ្នែក ទៅតាមបណ្តុំនៃសម្ភារ រួមមាន សំលៀកបំពាក់ ឧបករណ៍ផ្ទះបាយ ស្បែកកជើង នឹងសម្ភារជាច្រើនមុខតាមអាយុ តាមប្រភេទ និងតាមតម្លៃ ។

កញ្ញា បានបន្តថា ទំនិញទាំងនេះភាគច្រើន នាំចូលមកពីប្រទេសជប៉ុន ដែលមានគុណភាពល្អ និងតម្លៃអាចទទួលយកបាន សម្រាប់កម្រិតជីវភាពរបស់ប្រជាជនកម្ពុជា។

កញ្ញា បានបន្តថា រាល់មុខទំនិញដែលមានលក់នៅហាងសាគូ៉រា មានចាប់ពីតម្លៃ ៤០០០រៀល (USD1) ឡើងទៅ។

កញ្ញា បានបន្តថា ក្រៅពីមាន ហាងលក់ផ្លូវការ មានសាខាមានទីតាំង ច្បាស់លាស់ ហើយនោះ សាគូ៉រា ក៏មាននូវគេហទំព័រ សម្រាប់ជម្រាបព័ត៌មានអំពីផលិតផលនានា ជូនដល់អតិថិជន ជាច្រើនផងដែរ ។

លោកស្រី នុប សារួន ជាស្ត្រីមេផ្ទះមួយរូប បាននិយាយនៅពេលដែលចូលហាងសាគូ៉រា នៅម្តុំបឹងត្របែក កាលពីពេលថ្មីៗនេះថា កែវ ចាន ស្លាបព្រាល្អៗ បើយើងទៅទិញនៅផ្សារគឺថ្លៃ ដោយខ្លះដល់ខ្ទង់រយដុល្លារផងក៏មាន ប៉ុន្តែនៅទីនេះ យើងចំណាយត្រឹម ១០ដុល្លារ គឺអាចបានមួយឈុត សម្រាប់ប្រើប្រាស់ ។

លោកស្រីបានបញ្ជាក់ថា "ខ្ញុំធ្លាប់ទិញបាន ឆ្នាំងបាយ និងចង្ក្រានអគ្គិសនីមួយ សឹងតែថ្មី តម្លៃត្រឹមតែ ៥ ដុល្លារប៉ុណ្ណោះ ខណៈនៅផ្សារទំនើបខ្លះ ឆ្នាំងនេះ ចង្ក្រាននេះចំណាយ ដល់ ៥០ ទៅ ៦០ ដុល្លារ មិនអាចទិញបានផង"។

លោកស្រីបានបន្តថា មានរបស់ជជុះប្រើប្រាស់ គឺវាអាចជួយសម្រួលជីវភាពប្រជាពលរដ្ឋបានច្រើនដែរ ជាពិសេសអ្នកដែលមានចំណូលទាប ។

*ដោយ : អរិយបុត្រ*

## ស្ថានភាពប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកម្ពុជា

កម្រិតប្រាក់ចំណូលរបស់ប្រជាពលរដ្ឋកម្ពុជានៅក្នុងឆ្នាំ២០១៦នេះ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជា ព្យាករណ៍ថា នឹងឡើងដល់ ១.៣០០ដុល្លារ ។

សម្ដេចតេជោ ហ៊ុន សែន ធ្លាប់បានមានប្រសាសន៍កាលពីពេលថ្មីៗកន្លងទៅនេះ កម្រិតប្រាក់ចំណូល របស់ប្រជាពលរដ្ឋកម្ពុជាម្នាក់ៗ កាលពីឆ្នាំ២០១៥ គឺនៅក្នុងមួយឆ្នាំអាចរកបានត្រឹមតែប្រមាណជា ១.២១៥ ដុល្លារនៅក្នុងមួយឆ្នាំ ប៉ុន្តែ រំពឹងថានឹងឡើដល់ ១.៣០១ ដុល្លារ នៅឆ្នាំនេះ ។

លោក ស៊ុន ចាន់ថុល ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន បាននិយាយកិច្ចប្រជុំលើកទី៣៧នៃគណៈកម្មាធិការសមាគមកំពង់ផែអាស៊ានថា ជាមួយនឹងសន្ទុះនៃកំណើនសេដ្ឋកិច្ច នៅក្នុងរង្វង់មួយឆ្នាំ៧ ភាគរយ កម្ពុជាអាចនឹងរំដោះខ្លួនចេញផុតពី ប្រទេសដែលមានប្រាក់ចំណូលទាបនេះ នៅឆ្នាំ២០៥០។ លោកបានថ្លែងថា នៅក្នុងឆ្នាំ២០១៦ នេះកម្ពុជាបានរើខ្លួនចេញពីប្រទេសដែលមានចំណូលទាបមកជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបមួយ ហើយកម្ពុជាកំពុងតែប្រែក្លាយខ្លួន ដើម្បីទៅជាប្រទេសដែលមានចំណូលខ្ពស់នៅក្នុងឆ្នាំ២០៥០។

លោក ជេញ ហេងរតនា អាជីវករ មួយរូប បានថ្លែងថា ១.៣០០ដុល្លារនៅក្នុងមួយចំនួន មិនអាចគ្រប់គ្រាន់នឹងឲ្យពលរដ្ឋបំភ្លេចរបស់ជជុះណាស់ លុះត្រាតែ ១៣.០០០ ដុល្លារ ប្រហែលបាន។ ចំណូលត្រឹមតែ ប៉ុណ្ណឹង បើនិយាយត្រឹមតែ បរិភោគ គឺពិបាកចុះនៅថ្លៃសេវាសុខភាព និង ការចំណាយផ្សេងៗ។

## ទំនិញជជុះមិនមែនជាបញ្ហាតែនៅកម្ពុជានោះទេ ជាបញ្ហាប្រទេសក្រីក្រ

ទំនិញជជុះនេះមិនមែនជាបញ្ហាតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះនោះទេ វាគឺជាបញ្ហានៅប្រទេសក្រីក្រដែលខ្វះខាត។ លោក ទេព សិទ្ធិ ជាប្រជាពលរដ្ឋកម្ពុជាមួយរូបបានមានប្រសាសន៍ថា ពីដំបូងខ្ញុំគិតថា នេះជាបញ្ហាតែសម្រាប់កម្ពុជា ប៉ុន្តែថ្មីៗកន្លងទៅនេះ ខ្ញុំធ្លាប់បានអានអត្ថបទមួយចំនួន ដែលនិយាយអំពី ផលប៉ះពាល់ នៃទំនិញជជុះនេះនៅប្រទេសមួយចំនួន រួមទាំងឥណ្ឌូនេស៊ី។

លោកបានបន្តថា ផលប៉ះពាល់នៃទំនិញជជុះនេះអត់មានអីខុសគ្នាទេ គឺកង្វល់អំពីសរាមរបស់ប្រទេសអ្នកមាន និងផលប៉ះពាល់អំពីបរិស្ថាននេះឯង ។

លោកបានបញ្ជាក់ថា "ដូចនៅឥណ្ឌូនេស៊ីអី តាមព័ត៌មានថា រដ្ឋាភិបាលក៏មានផែនការបញ្ឈប់ការនាំចូលរបស់ជជុះនេះដែរ តែពលរដ្ឋជំទាស់ដោយសារតែជីវភាពនេះឯង"។

លោក ជេញ ហេងរតនា អាជីវករមួយរូបបានបន្តថា រឿងសំរាមវា គឺជារឿងគេចមិនផុតទេ តែតាមខ្ញុំសង្កេត ឃើញថាអាសំណល់នៃរបស់ជជុះអស់តម្លៃមួយចំនួន ក៏ត្រូវបានគេរើសលក់អេតចាយនាំចេញទៅវៀតណាមដែរ សម្រាប់យកទៅកែច្នៃឡើងវិញ ។

# JSC ដាំកូនឈើតំបន់ព្រៃលិចទឹកក្នុងខេត្តកំពង់ធំ







ថតដោយៈ សុវណ្ណា

អង្គការ JSC បានរួមសហការជាមួយ អាជ្ញាធរមូលដ្ឋាន ប្រជាពលរដ្ឋ សិស្សានុសិស្ស គ្រូបង្រៀន គណៈកម្មការវត្ត កំពង់ចំលង យោធាក្នុងតំបន់ សរុបទាំងអស់ប្រមាណជិត ១០០នាក់ បានដាំកូនឈើចំនួន ជាង៥០០ដើម នៅតំបន់ព្រៃលិចទឹក ក្នុងឃុំផាត់សណ្តាយ ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំកាលពីថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៦កន្លងទៅ។

លោក ហេង មនោ ជាមេឃុំផាត់សណ្តាយ បានមានប្រសាសន៍ថា ទីតាំងភូមិសាស្ត្រក្នុងឃុំនេះមានព្រៃលិចទឹកប្រមាណជាង ៣០០០០ហិតា។

តែព្រៃទាំងនេះរងការបំផ្លាញ ដោយមូលហេតុផ្សេងៗមានដូចជា ការចូលតាំងទីលំនៅដោយខុសច្បាប់របស់ពលរដ្ឋចំណាកស្រុក។ ការកាប់គាស់ដើម្បីធ្វើចំការពេលទឹកស្រក។ ការបំផ្លាញ់ខ្លាំងបំផុត គឺការដុះព្រៃរបស់អ្នករកចាប់សត្វអណ្តើក និងឃ្មុំជាដើម ដែលក្នុងដើមឆ្នាំ ២០១៦ គឺព្រៃត្រូវបំផ្លាញដោយការដុះនេះអស់រាប់រយហិតា។ លោកបន្តថា ដោយសារឆ្នាំនេះមានអាកាសធាតុក្តៅខ្លាំងងាយឆេះរាលខ្លាំងណាស់។

លោកមេឃុំ ក្នុងនាមអាជ្ញាធរឃុំសូមអំពាវនាវឲ្យពលរដ្ឋទាំងអស់ចូលរួមថែរក្សា នឹងចូលរួមដាំកូនឈើក្នុងព្រៃលិចទឹកឡើងវិញ។ ក្នុងនោះលោកក៏អំពាវនាវឲ្យមានអ្នកដែលស្រឡាញ់ធម្មជាតិបរិស្ថានចូលរួមថែរក្សា និងឧបត្ថម្ភការជាអប់រំ សម្ភារៈ និងថវិការដល់អ្នកការពារ។

ឃុំផាត់សណ្តាយ ប្រជាជនមានប្រមាណជាង ៥០០០នាក់ មានគ្រួសាចំនួនប្រមាណ ១២៤៧គ្រួសារ ដែល ៩៥% ជាអ្នកនេសាទ។ ប្រជាពលរដ្ឋទាំងនោះមានផ្ទះនៅលើទឹក។

តាមលោកមេឃុំ ព្រៃលិចទឹក ជាធន់ធានធម្មជាតិយ៉ាងសំខាន់ សម្រាប់ទប់ល្បាប់កុំឲ្យហូរចូលលឿនពេកទៅក្នុងបឹងទន្លេសាប។ ជាងនេះ ព្រៃលិចទឹកមានសំខាន់ណាស់សម្រាប់អ្នករស់នៅលើទឹក និងជាអ្នកទន្លេ។ អ្នកទន្លេជាអ្នកស្រឡាញ់ព្រៃលិចទឹកណាស់ ព្រោះជាជំរកត្រីពងកូន ដោយសារគេរស់ ពឹងលើរបរចាប់ត្រី។ ម្យ៉ាងទៀត ព្រៃលិចទឹកជារបាំងការពារខ្យល់ព្យុះ ការពាររលកទឹកធំៗ មកប៉ះផ្ទះ និងភូមិរបស់គេ។ លោក ហេង មនោ ថា "អ្នកដីគោក ស្រឡាញ់ដី តែអ្នកទន្លេដូចយើង គឺស្រឡាញ់ព្រៃលិចទឹកណាស់"។

លោកក៏មិនភ្លេចអង្គការ JSC ផ្នែកបរិស្ថាន ដែលជួយក្នុងឃុំផាត់សណ្តាយនេះ មិនត្រឹមតែបំផុសឲ្យពលរដ្ឋដាំកូនឈើគឺបានទាំង ជួយកសាងសមិទ្ធផលផ្សេងទៀតដែរដូចជាជួយសាលារៀនជាដើម។

បើតាមប្រសាសន៍របស់ លោក សេង សុជាតា ជាមន្ត្រីផ្នែកបរិស្ថានរបស់អង្គការ JSC បានឲ្យដឹងថា ការដាំព្រៃឈើនៅក្នុងឃុំផាត់សណ្តាយនេះបាន ៤ ដងរួចមកហើយ គឺតាំងពីឆ្នាំ២០១៤មក។ លើកនេះកូនឈើ ដែលបានដាំនៅពេលនេះមានប្រភេទកូនរាំង និងតាអួ ដែលជារុក្ខជាតិដុះក្នុងទឹកបាន មានចំនួនជាង ៥០០ដើម។ កូនឈើទាំងនេះ គឺបណ្តុះក្នុងកសិដ្ឋានបណ្តុះកូនឈើរបស់អង្គការ JSC នៅក្នុងស្រុកអង្គស្នួលខេត្តកណ្តាល។ មន្ត្រីរូបនេះបន្តថា អង្គការ JSC ផ្នែកបរិស្ថានបានដាំកូនឈើជាច្រើនកន្លែង ដូចជាការដាំកូនឈើ ការពាររួមជាមួយសហគមន៍នៅព្រៃឡង់ ប្រចាំនៅខេត្តព្រះវិហារ បានដាំកូនឈើនៅតាមវត្តតាមសាលានៅកំពង់ស្ពឺ ព្រៃវែង ពោធិ៍សាត់ និងតំបន់ព្រៃលិចទឹក ឃុំផាត់សណ្តាយនេះ។

យុវសិស្សសៀន ឆេងលី សិស្សថ្នាក់ទី៩ នៃអនុវិទ្យាល័យ ផាត់សណ្តាយ ដែលបានចូលរួមដាំកូនឈើក្នុងពេលនេះបាននិយាយថា នាងរីករាយណាស់ដែលមានឱកាសចូលរួមដាំកូនឈើថ្ងៃនេះ ព្រោះនាងស្រឡាញ់ធម្មជាតិ ជាពិសេសព្រៃលិចទឹកនេះ។ នាងថា មានព្រៃលិចទឹក មានត្រីច្រើន មានត្រីច្រើនជីវភាពអ្នកទន្លេ ដូចនាង គឺរីករាយណាស់។

ចំណែក អ្នកស្រី ខាត់ សុខុម ជាពលរដ្ឋក្នុងឃុំនេះ ហើយធ្លាប់ចូលរួមដាំកូនឈើកន្លងមកដែរ បាននិយាយថា ពិតជារីករាយ ក្នុងការចូលរួម ការពារ ចូលរួមដាំ ព្រៃលិចទឹកនេះណាស់ព្រោះជាជំរកសម្រាប់ត្រីពងកូន។ ការពារកំដៅកុំឲ្យក្តៅខ្លាំង និងជារនាំងការពារផ្ទះសំបែងរបស់យើងពីខ្យល់ព្យុះ និងរលកធំៗដែរ។ អ្នកស្រីសូមអំពាវនាវកុំឲ្យមានការដុះបំផ្លាញព្រៃលិចទឹក និងរួមគ្នាដាំឡើងវិញ។

ឃុំផាត់សណ្តាយមានទីតាំង ជាប់ជាមួយឃុំកំពង់គោ ជាប់ជាមួយ ឃុំពាងបាំង ស្រុកស្ទោង ជាប់ជាមួយស្រុក កំពង់លែង និងឃុំឆ្នុកទ្រូ ស្រុកបរិបូរណ៍ ខេត្តកំពងឆ្នាំង និងមួយផ្នែកដែនទឹកជាប់ជាមួយខេត្តពោធិសាត់។ ឃុំផាត់ សណ្តាយ មានសក្តានុពលសិដ្ឋកិច្ច យ៉ាងសំខាន់ផងដែរផ្នែកជលផល និងកសិកម្ម។

*ដោយ សុវណ្ណា*

# ព្រះសហគមន៍បាត់ដំបង ពិធីបុណ្យព្រះម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ



នៅព្រះវិហារព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ នៃព្រះសហគមន៍កាតូលិកបាត់ដំបង កាលពីព្រឹកថ្ងៃទី១៤ ខែសីហា ឆ្នាំ២០១៦នេះ បានរៀបចំពិធីបុណ្យហែរូបសំណាកព្រះនាងម៉ារី ក្នុងឱកាសបុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ដោយមានការចូលរួមជាអធិបតីពីសំណាក់លោកអភិបាលអេនរីគេ ហ្វីការេដូ អភិបាលព្រះសហគមន៍កាតូលិកភូមិភាគបាត់ដំបង។

នៅមុនថ្ងៃពិធីបុណ្យនេះ ចាប់ពីថ្ងៃទី១០ ខែសីហាមក គ្រីស្តបរិស័ទក្នុងព្រះសហគមន៍កាតូលិកបាត់ដំបង បានរៀបចំអធិដ្ឋាននៅមុខរូបសំណាកព្រះនាងម៉ារីតាមវេន ដោយបន្តពីផ្ទះមួយទៅផ្ទះមួយតាមជំនឿកាតូលិក។ គ្រីស្តបរិស័ទតែងប្រារព្ធការអធិដ្ឋានរបៀបនេះជាយូរឆ្នាំមក ហើយជារៀងរាល់ល្ងាច គឺនៅមុនថ្ងៃបុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខនេះ។

ពិធីបុណ្យបានចាប់ផ្តើមដោយហែរូបសំណាក់ព្រះនាងម៉ារីចេញពីផ្ទះគ្រីស្តបរិស័ទដែលទទួលរៀបចំអធិដ្ឋានចុងក្រោយគេ ឆ្ពោះមកព្រះវិហារ។ ក្នុងក្បួនដង្ហែមានបាននាំមុខក្រុមឆៃយ៉ាំ ក្រុមរបាំបូរាណ និងគ្រីស្តបរិស័ទយ៉ាងច្រើនកុះករ។

នៅក្នុងធម្មទេសនាលោកអភិបាលអេនរីគ បានមានប្រសាសន៍ ទៅកាន់គ្រីស្តបរិស័ទថា នៅថ្ងៃនេះគឺជាថ្ងៃបុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារីឡើងស្ថានបរមសុខ ហើយព្រះសហគមន៍តែងតែប្រារព្ធពិធីនេះជារៀងរហូតមក ដើម្បីរំលឹកដល់ព្រះនាងម៉ារី ដែលជាបុព្វបុរសនៃជំនឿរបស់យើង និងជាឧបការីនៃព្រះសហគមន៍បាត់ដំបង។ ព្រះនាងម៉ារី ជាមនុស្សល្អស្អាត មានចិត្តបរិសុទ្ធ ហើយដែលមិនមានជាប់បាបកម្ម។ ព្រះនាងម៉ារីមានរបៀបរស់នៅ គឺបានដាក់ខ្លួន និងបន្ទាបខ្លួន ជាអ្នកបម្រើដោយចិត្តសុភាពរាបសា។ នាពេលសព្វថ្ងៃនេះ យើងម្នាក់ៗ រស់នៅក្នុងសង្គម ជាពិសេសយុវវ័យ ដែលកំពុងរស់នៅក្នុងភាពហ៊ឺហារ មានការប្រើប្រាស់សម្ភារសម័យទំនើបៗប៉ុន្តែយើងភ្លេចនូវគំរូដ៏ល្អរបស់ព្រះនាងម៉ារី ។

លោកបន្តថា ចូរម្នាក់ៗបានទទួលនូវគំរូនៃជំនឿរបស់ព្រះនាងម៉ារី។ ម្នាក់ៗត្រូវសម្លឹងមើលអំពីគំរូរបស់ព្រះនាងម៉ារីដែលជួយលើកទឹកចិត្តយើងម្នាក់ៗ នៅក្នុងជីវិតរស់នៅជារៀងរាល់ថ្ងៃ។ ទន្ទឹមនឹងនេះ លោកក៏មានប្រសាសន៍ជួយក្រើនរំលឹកសម្រាប់សមាជិកគណៈកម្មការព្រះសហគមន៍ គឺយើងត្រូវចេះរួបរួមគ្នាចេះសហការគ្នា កុំមានភាពច្រណែលឈ្នានីសគ្នា ឈ្លោះប្រកែកគ្នា ដោយដាក់ខ្លួនបន្ទាបខ្លួនបម្រើព្រះសហគមន៍ គឺយកគំរូតាមព្រះនាងម៉ារី។

ក្នុងប្រតិទិនរបស់ព្រះសហគមន៍កាតូលិក បានកំណត់យក ថ្ងៃទី១៥ សីហា ដើម្បីប្រារព្ធបុណ្យព្រះជាម្ចាស់លើកព្រះនាងម៉ារី ឡើងស្ថានបរមសុខយ៉ាងឱឡារឹក។ ដោយឡែកក្នុងឆ្នាំនេះព្រះសហគមន៍កាតូលិកកម្ពុជា បានប្រារព្ធមុនព្រោះថ្ងៃទី១៤ សីហា ត្រូវនឹងថ្ងៃអាទិត្យ ជាថ្ងៃដែលគ្រីស្តបរិស័ទត្រូវមកព្រះវិហារដើម្បីអភិបូជា ដូចនេះព្រះសហគមន៍បានប្រារព្ធបុណ្យនេះមុនមួយថ្ងៃ។ គ្រីស្តបរិស័ទកាតូលិកជឿថាព្រះជាម្ចាស់បានលើព្រះនាងម៉ារីឡើងស្ថានបរមសុខទាំងរូបកាយនិងវិញ្ញាណ។

# ដំណើរកម្សាន្តទៅខេត្តសៀមរាបរបស់យុវជននិងកុមាររបស់ព្រះសហគមន៍កំពង់គោ



ថតដោយ ហ្វេសប៊ុក

យុវជន គ្រូអប់រំជំនឿ និងកុមារនៃអង្គការកុមានមេគង្គប្រមាណជា៤៥នាក់នៃព្រះសហគមន៍ កំពង់គោ ដែលស្ថិតនៅក្នុង ភូមិកំពង់គោក្រោម ស្រុកកំពង់ស្វាយ ខេត្តកំពង់ធំ បានធ្វើដំណើរកម្សាន្តទៅកាន់ទឹកដីអង្គរខេត្តសៀមរាប កាលពីថ្ងៃទី១៧ សីហា ២០១៦កន្លងទៅនេះ។

បងស្រីគឹមឡេក ជីវ៉ានាន់បានឲ្យដឹងថា ដំណើរកម្សាន្តនេះគឺមានរយៈពេលតែមួយថ្ងៃទេព្រោះតែយើងមិនសូវជាមានពេលច្រើន។ បងស្រីបន្តថាតែក្នុងនោះយើងមានបំណងចង់ឲ្យក្មេងៗ និងយុវជនមានពេលដើរមើលប្រាសាទបុរាណរបស់ខ្មែរ ជាពិសេសប្រាសាទអង្គរវត្តដែលជាកន្លែងវប្បធម៌ និងប្រវត្តសាស្ត្ររបស់ប្រទេសកម្ពុជា។ វាជាឱកាសល្អព្រោះមិនត្រឹមតែកម្មវិធីសប្បាយជាមួយគ្នាតែវាក៏ជាការផ្តល់ចំណេះដឹងម្យ៉ាងថា ដូនតាជំនាន់មុនលោកបានសាងសង់អ្វីខ្លះ? មានស្នាដៃអ្វីខ្លះទុកឲ្យកូនខ្មែរជំនាន់ក្រោយចងចាំទុកក្នុងចិត្ត។

បងស្រីរូបនេះបន្ថែមថា នេះជាលើកទីមួយសម្រាប់ក្រុមនេះក្នុងដំណើរកម្សាន្តរួមគ្នាបែបនេះ ហើយការធ្វើបែបនេះ គឺយើងចង់លើកទឹកចិត្តពួកគេ ក៏ដូចជាផ្លាស់ប្តូរបរិយាកាសម្តងនៅពេលដែលឃើញកុមារយុវជន និងគ្រូអប់រំជំនឿទាំងនោះខិតខំជួយកម្មវិធីផ្សេងៗក្នុងព្រះវិហារដោយ មិនគិតពីការនឿយហត់។

កម្មវិធីនេះក៏មានការចូលរួមពីសំណាក់លោកបូជាចារ្យចនឡេស្ទើរ តាយុន អ្នកស្ម័គ្រចិត្តនៃអង្គការកុមារមេគង្គផងដែរ។

*កញ្ញា ឃីហុកស៊ីវ*

# ពិធីបិទឆ្នាំសិក្សា សម្រាប់សិស្សអប់រំជំនឿនៃព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច


ថតដោយ សម្ផស្ស

ពិធីបិទឆ្នាំសិក្សា សម្រាប់សិស្សអប់រំជំនឿ កាលពីព្រឹកថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៦នេះ ក្រោយពីបានចូលរួមការស្វែងយល់ និងទទួលការអប់រំជំនឿអស់មួយរយៈពេលមួយឆ្នាំកន្លងមក។ កម្មវិធីណេះរៀបចំឡើងដោយ នៃគណៈកម្មការអប់រំជំនឿ នៃព្រះសហគមន៍កាតូលិកសន្តយ៉ូសែប ផ្សារតូច និងមានសិស្សអប់រំជំនឿចូលរួម ប្រមាណជាង ២០០នាក់ ។

លោកបូជាចារ្យរឿង ធ័ត្រសិរី ជាបូជាចារ្យទទួលខុសត្រូវនៅព្រះសហគមន៍សន្តយ៉ូសែប បានឲ្យដឹងថា លោកមានអំណរសប្បាយរីករាយជាខ្លាំង ដោយបានឃើញប្អូនៗ ជាច្រើនបានជួបជុំគ្នានៅក្នុងពិធីបិទឆ្នាំសិក្សានាពេលនេះ។ ប្អូនៗបានចូលរួមជាមួយព្រះសហគមន៍ តាមរយៈការស្វែងយល់ជំនឿ នៅព្រះសហគមន៍យើងនេះ។ យើងទាំងអស់គ្នាបានដឹងហើយថា យើងស្រឡាញ់ព្រះជាម្ចាស់ ហើយយើងក៏កំពុងដើរតាមព្រះយេស៊ូ ដោយយកចិត្តទុកដាក់ទទួលការអប់រំជំនឿពីលោកគ្រូអ្នកគ្រូរបស់យើង ។

លោកបានបន្ថែមថា កាលដែលយើងមកទទួលការស្វែងយល់ជំនឿនៅព្រះសហគមន៍ គឺយើងបានទទួលនូវបទពិសោធន៍បន្ថែមទៀតអំពីលោកគ្រូអ្នកគ្រូនូវជំនឿ សេចក្តីស្រឡាញ់ និងចិត្តមេត្តាករុណា ដែលបានមកពីព្រះជាម្ចាស់។ លោកបូជាចារ្យរូបនេះបានសង្កត់ធ្ងន់ថា នៅពេលយើងទទួលការអប់រំជំនឿ គឺយើងត្រូវប្រើប្រាស់នូវសរីរាង្គបីនោះគឺ ខួរក្បាល បេះដូង និងដៃរបស់យើង ពោលគឺនៅពេលដែលយើងទទួលការណែនាំជំនឿពីលោកគ្រូអ្នកគ្រូ គឺយើងទទួលទុកក្នុងខួរក្បាលរបស់យើង ហើយវាបានដក់នៅក្នុងដួងចិត្ត (នៃបេះដូង) យើងជានិច្ចនូវសេចក្តីស្រឡាញ់ព្រះជាម្ចាស់ ប៉ុន្តែយើងកុំភ្លេចថា អ្វីៗដែលយើងបានទទួលចូរយើងប្រើប្រាស់ដៃរបស់យើង សម្រាប់ចែក រំលែកជាមួយអ្នកដទៃ។

លោកបានបញ្ជាក់ថា នៅពេលនេះយើងសម្រាកមួយរយៈពីការអប់រំជំនឿក៏ពិតមែនប៉ុន្តែកុំភ្លេច ចូរយើងធ្វើការអធិដ្ឋាន និងចូលរួមថ្វាយអភិបូជាជារៀងរាល់ថ្ងៃអាទិត្យ ដើម្បីលើកតម្កើង និងអរព្រះគុណព្រះជាម្ចាស់។ ជាមួយគ្នានេះលោកគ្រូខេមរិន្ទ ដែលតំណាងឲ្យគណៈកម្មការអប់រំជំនឿ នៃព្រះសហគមន៍កាតូលិកសន្តយ៉ូសែបបានឲ្យដឹងថា លោកសូមថ្លែងអំណរគុណចំពោះលោកគ្រូអ្នកគ្រូទាំងអស់បងស្រី និងលោកបូជាចារ្យដែលបានខំចំណាយពេលវេលាចូលរួមជួយណែនាំ និងអប់រំជំនឿប្អូនៗនាឆ្នាំនេះដោយយកចិត្តទុកដាក់។ លោកបន្តថា ក្នុងពិធីបិទឆ្នាំសិក្សានាឆ្នាំនេះ គណៈកម្មការគ្រូអប់រំជំនឿបានរិះគិតជាមួយគ្នាក្នុងការរៀបចំ ឲ្យមានកម្មវិធីលើកទឹកចិត្តតាមរយៈការផ្តល់ជាកាដូជូនដល់ប្អូនៗ ដែលមានវត្តមានច្រើនជាងគេ នៅក្នុងការចូលរួមទទួលការអប់រំជំនឿ ក្នុងរយៈពេលកន្លងមក។

ប្អូនប្រុស ចាន់ បុរី ជាសិស្សទទួលការអប់រំជំនឿនៃព្រះសហគមន៍សន្តយ៉ូសែប ផ្សារតូច បានឡើងចាប់អារម្មណ៍ថា ក្នុងនាមប្អូន ជាសិស្សដែលទទួលការអប់រំជំនឿ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកបូជាចារ្យ បងស្រី លោកគ្រូអ្នកគ្រូទាំងអស់ដែលជួយបន្តជំនឿមកដល់ប្អូនៗ ទាំងអស់គ្នា គឺជួយប្អូនឲ្យបានស្គាល់ព្រះយេស៊ូ ស្គាល់ព្រះជាម្ចាស់បានរៀន និងយល់អំពីអត្ថន័យនៃព្រះគម្ពីរ ព្រមទាំងសេចក្តីស្រឡាញ់ របស់ព្រះយេស៊ូចំពោះយើងទាំងអស់គ្នា។ ប្អូនបានបន្តថា ប្អូនប្តេជ្ញាថា នឹងយកព្រះបន្ទូលរបស់ព្រះយេស៊ូ មកអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន នៅក្នុងការស្រឡាញ់ឪពុកម្តាយ និងស្រឡាញ់អ្នកជិតខាងរបស់ខ្លួន ។

សូមបញ្ជាក់ថា សម្រាប់កម្មវិធីអប់រំជំនឿនាឱកាសឆ្នាំសិក្សាថ្មី និងចាប់ផ្តើមនៅដើមខែកញ្ញាខាងមុខនេះ។ ហើយជាមួយគ្នានេះ នៅថ្ងៃទី១១-១៥ ខែសីហា៕

*ដោយ សម្ផស្ស*

# អបអរសាទរយុវតីពិការអ៊ែក ស្រីមុំប្រឡងជាប់មធ្យមសិក្សាទុតិយភូមិ



យុវតីពិការនៃភូមិសុខសាន្ត និងជាសិស្សឆ្នើមនៃវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ ខេត្តកាកែវអ៊ែកស្រីមុំបានធ្វើឲ្យមនុស្សជាច្រើនមានការភ្ញាក់ផ្អើលនិងស្ងើចសរសើរនាងដែលបានតស៊ូរៀនរហូតប្រឡងជាប់មធ្យមសិក្សាទុតិយភូមិនាពេលថ្មីៗនេះ។

ស្រីមុំជាក្មេងស្រីខិតខំរៀនសូត្រទោះបីជាពិការជើងទាំងពីរតាំងពីកំណើតក៏ដោយ ក៏នាងតែងតែខ្នះខ្នែងក្នុងការសិក្សាជានិច្ច ដោយនិយាយថា "មានតែចំណេះវិជ្ជាទេដែលអាចជួយយើងបាននាពេលអនាគត"។ ស្រីមុំបន្តថា ទោះបីជាកាយសម្បទាពិការមែនតែនាងមិនអស់សង្ឃឹមនោះឡើយនាងនៅតែតស៊ូរៀនដោយមានសង្ឃឹមថា នឹងអាចចូលរួមធ្វើការងារនៅក្នុងសង្គមបាន។

ស្រីមុំនិយាយថា វិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ បានជួយច្រើនដល់នាងក្នុងការសិក្សា ដោយមានទាំងគ្រូដែលមានបទពិសោធន៍ល្អៗជាច្រើនឆ្នាំ និងមានកម្មវិធីលើកទឹកចិត្តដល់សិស្សពូកែព្រមទាំងផ្តល់ឯកសណ្ឋាន និងអាហារថ្ងៃត្រង់ដល់សិស្សគ្រប់គ្នាដែលជាកត្តាមួយក្នុងការជំរុញ និងលើកទឹកចិត្តឲ្យខិតខំរៀនបន្តទៀត។

តាមរយៈវិទ្យាល័យសន្ត ហ្វ្រង់ស្វ័រ ស្រីមុំមានឱកាសច្រើនក្នុងការរៀនសូត្រ ជាពិសេសអាចជួយសម្រួលដល់បន្ទុកគ្រួសារបានថែមមួយកំរិតទៀតដោយនាងបានចូលទៅរស់នៅក្នុងមណ្ឌលជនពិការ "ភូមិសុខសាន្ត" នៃព្រះសហគមន៍កាតូលិក។

យុវតីពិការអ៊ែក ស្រីមុំ ជាបេក្ខជនមួយរូប ក្នុងចំណោមសិស្សានុសិស្សចំនួន ៣៥នាក់ស្រី១៩នាក់ វិទ្យាល័យចំណេះដឹងទូទៅបច្ចេកទេសឯកជនសន្ត ហ្វ្រង់ស្វ័រ ដែលបានចូលរួមប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិឆ្នាំនេះ។ រីឯបេក្ខជនប្រឡងជាប់មានចំនួន ៣២នាក់ ស្រី ១៧នាក់ គិតជាភាគរយមាន ៩១.៤២% ក្នុងនោះនិទ្ទេសBចំនួន២នាក់ និទ្ទេសC ចំនួន១២នាក់ និទ្ទេសDចំនួន២នាក់ និងនិទ្ទេសE ចំនួន១៦នាក់។

តាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអប់រំយុវជន និងកីឡាបានឲ្យដឹងថា សម្រាប់ការប្រលងបាក់ឌុបឆ្នាំ ២០១៦នេះបេក្ខជនសរុបមានប្រមាណ ៩១០៥១នាក់ ដោយក្នុងនោះបេក្ខជនចំនួន៧០២៤៣នាក់ មកពីគ្រឹះស្ថានសិក្សាឯកជន និងបេក្ខជនចំនួន១៥៨៦១នាក់ជាបេក្ខជនស្សេរីន។ បេក្ខជនដែលប្រឡងជាប់មានចំនួន ៥៥៧៥៣នាក់ ត្រូវជា៦២,១៨% នៃបេក្ខជនវត្តមានចំនួន ៨៩៦៦១នាក់។ បេក្ខជនដែលមាន និទ្ទេសAចំនួន៤០៥នាក់ និទ្ទេស Bចំនួន២៨០១នាក់ និងនិទ្ទេស C ចំនួន ៥៥៩៥នាក់ និទ្ទេស D ចំនួន ៨៨៣៥នាក់ និងនិទ្ទេសE មានចំនួន ៣៨១១៧នាក់។

*ដោយ ដាលីស*

# ណូអែល ក្រានិក (១៩១៨-១៩៧០)

## Père Noel GRANNEC

## លោកបូជាចារ្យសាសនទូតក្រៅប្រទេសនាក្រុងប៉ារីស



លោកណូអែល ក្រានិក កើតនៅថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩១៨ នៅភ្លៃបែន (ហ្វីនីសតែរ) Pleyben (Finistere) នៃព្រះសហគមន៍កាតូលិកភូមិភាគកែមពែរ (Quimper)។

ឆ្នាំ ១៩៤៤ លោកបានចូលរៀននៅទេវវិទ្យាល័យរបស់សាសនទូតក្រៅប្រទេសនាក្រុងបារីស។

ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ១៩៤៧ លោកបានទទួលការតែងតាំងជាបូជាចារ្យ ។

ថ្ងៃទី១២ វិច្ឆិកា ១៩៤៨ លោកបានធ្វើដំណើរទៅបំពេញមុខងារនៅទីក្រុងហាណូយ។ ក្រោយពីបានរៀនភាសា លោកបានទទួលការជ្រើសតាំងជាអ្នកទទួលខុសត្រូវព្រះសហគមន៍អន់តួន នៅទីក្រុងហាណូយ។

ឆ្នាំ១៩៥៣ លោកបានធ្លាក់ខ្លួនឈឺ ហើយត្រូវមកព្យាបាលនៅដាឡាដ។ទីបំផុតលោកមិនដែលបានវិលត្រឡប់ទៅទីក្រុងហាណូយបានឡើយ អាស្រ័យដោយសង្គ្រាមឥណ្ឌូចិនដ៏ក្ដៅគគុក។

ឆ្នាំ ១៩៥៣ លោក ណូអែល ក្រានិក ត្រូវបានបញ្ជូនមកបំពេញមុខងារនៅប្រទេសកម្ពុជា លោករៀនភាសាខ្មែរនៅបាណាម ហើយលោកពេញចិត្តបំពេញមុខងារនៅជប់។ ជប់ជាតំបន់ចំការ កៅស៊ូដ៏ធំល្វឹងល្វើយ គ្រប់គ្រងដោយក្រុមហ៊ុន មីសឺលីន (Societe Michelin)។

គ្រីស្ដបរិស័ទនៅជប់ គឺជាពលករចាក់ជ័រកៅស៊ូមកពីវៀតណាមខាងជើង ពួកគេនិយាយភាសា របស់គេ និងរក្សាប្រពៃណីជំនឿរបស់ពួកគេដោយផ្ទាល់ មិនស្ថិតនៅក្រោមការគ្រប់គ្រងរបស់ពួក អឺរ៉ុបនោះឡើយ។ របៀបគ្រប់គ្រងរដ្ឋបាលបែបអាណានិគមនិយមសម្រាប់កម្មករនៅតំបន់ចំការកៅស៊ូ ដែលមានព្រំប្រទល់ជាប់គ្នា គឺតឹងតែងខ្លាំងណាស់ គ្មានទំនាក់ទំនងអ្វីជាមួយប្រជាជនកម្ពុជា ដែលរស់នៅជុំវិញខ្លួននោះឡើយ។

លោកឪពុក ក្រានិក តែងតែទទួលយកហេតុផលរបស់កម្មករចំការកៅស៊ូ អំពីការកើតទុក្ខមិន សុខចិត្តរបស់ពួកគេចំពោះម្ចាស់ចំការ ជូនកាលណាលោកនាំការលំបាកទាំងនោះ មកជម្រាប លោកអភិបាល។

ស្ថានភាពសង្គមនៃចំការកៅស៊ូ ផ្ដល់អំណោយផលឲ្យពួកវៀតកុងជ្រៀតចូលដោយស្ងាត់ៗ។ លោកក្រានិក ត្រូវបានទទួលការចោទប្រកាន់ព្រមគ្នាទាំងសង្ខាង គឺទាំងពួកកុំម្មុយនីស្ដ ទាំងអ្នកមិនមែនកុំម្មុយនីស្ដ។

ឆ្នាំ ១៩៧០ លោកបានទទួលការជ្រើសតាំងជាបូជាចារ្យទទួលខុសត្រូវព្រះសហគមន៍ពានជរ (Vinh Loi) ជាសហគមន៍វៀតណាម នៅជាប់ទន្លេមេគង្គ។ សម័យនោះ ជាសម័យដែលពួកវៀតកុង មានវត្តមាននៅតាមព្រំដែនកម្ពុជា ហើយកំពុងតែលុកលុយរាតត្បាតទន្ទ្រានចូលក្នុងប្រទេសកម្ពុជា។

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ១៩៧០ លោកឪពុក ក្រានិក ត្រូវពួកវៀតកុងចាប់ខ្លួន ហើយធ្វើឃាតសម្លាប់លោកនៅអ្នកលឿង ។

---


សន្ត យ៉ូហាន បូស្កូ

លោកយ៉ូហាន បូស្កូ កើតក្នុងកសិដ្ឋានតូចមួយនៅទីក្រុងទូរីណូ នៅប្រទេសអ៊ីតាលី នៅឆ្នាំ១៨៥០។ ឪពុកម្ដាយគាត់មានជីវភាពក្រីក្រ។ ក្នុងមួយឆ្នាំយ៉ូហានដើរទៅ សាលារៀនប្រាំមួយខែ ហើយប្រាំមួយខែផ្សេងទៀត គាត់ជាកសិករធ្វើការនៅក្នុងស្រែ ចម្ការ ធ្វើជាជាងកាត់ដេរ អ្នកដុតនំប៉័ង ជាងស្បែកជើង ហើយនឹងជាជាងឈើ។ ធ្វើដូច្នេះគាត់បានសម្រេចការសិក្សានៅវិទ្យាល័យ មហាវិទ្យាល័យ និងចូលនៅក្នុងទេវវិទ្យាល័យ ហើយក្រោយមកគាត់ក្លាយជាបូជាចារ្យដោយមានបទពិសោធន៍ច្រើនណាស់។

យុវជនស្រឡាញ់លោកឪពុកយ៉ូហានខ្លាំងណាស់។ គាត់បានបង្កើតកន្លែងសម្រាប់ជួបជុំគ្នាលេងល្បែង និងអធិដ្ឋាន។ គាត់ជួលជង្រុកចាស់មួយនៅក្នុងជនបទ ដែលគាត់ ហៅថា៖ បន្ទប់អធិដ្ឋាន។ ជង្រុកនោះជាផ្ទះសម្រាប់យុវជន ជាពិសេសយុវជនដែល មកពីគ្រួសារក្រីក្រ និងត្រូវការផ្ទះសម្រាប់ស្នាក់នៅ។ ក្រោយមក គាត់បង្កើតកន្លែងបែបនេះជាច្រើនទៀត។ គាត់ជឿជាក់ថាប្រសិនបើយើងអប់រំយុវជនដោយមានចិត្តស្រឡាញ់ យុវជននោះអាចទៅជាយុវជនដ៏ល្អម្នាក់។ លោកបូស្កូបង្កើតក្រុមបពជិតមួយជាក្រុមបូជាចារ្យដែលជួយគាត់អប់រំយុវជននៅក្នុងប្រទេសជាច្រើន។ ពួកគាត់ជួយ យុវជនឲ្យមានការងារធ្វើ ហើយយុវជនជាច្រើនបានក្លាយទៅជាមេដឹកនាំនៅក្នុងសង្គម។ លោកបូស្កូជាគ្រីស្ដទូតនៃយុវវ័យ។

---

## កំណាព្យ ម្ដេចមិនប្រមាណខ្លួនផង

(បទពាក្យ ៧)



*និពន្ធដោយអ្នកស្រី ខុង ណារី, មន្ត្រីគ្រប់គ្រងកម្មវិធីអប់រំ និង សុខភាពនៃគម្រោងអភិវឌ្ឍន៍ជនបទ អង្គស្នួល/JSC*

១- ជាវុក្ខាជាតិនាមសង្កែ ពូជពង្សមិនខ្ពស់រស់គ្រសុំ
ដុះតាមភ្លឺស្រែក្បែរជើងភ្នំ ជាព្រៃជល្បុះភ្នំជុំព្រោងព្រាត។

២- ភ្នំភ្នែងព័ទ្ធពង់វង់មិនឆ្ងាយ ខ្លួនជាល្បុះភ្នំមិនចង់ឃ្លាត
ទឹកចិត្តសប្បាយដុះជួបញាតិ រួមរស់ក្បែរញាតិជាតុដូចគ្នា។

៣- ប្លែកតែសង្កែប្រែប្រាណចិត្ត ជួបនិងមហន្តរាយកាយវេទនា
ផ្ដោះផ្ដោងគំនិតឥតគិតគ្រា ភ្លេចភ្លាំងមួយគ្រាព្រោះលោភលន់។

៤- ឃើញដើមគគីដុះជើងភ្នំ បក្សាបក្សីទំដោជន់
លូតខ្ពស់ឡើងធំជុំល្អគន់ សមរាងពេកពន់ដើមស្លឹកមែក។

៥- សង្កែក្បែរនោះប្រឹងលូតតាម យកល្បះគគីទីតាំងដេក
គិតថានិងច្បាមឲ្យអនេក ពពួកសត្វត្រេកត្រអាលខ្លាំង។

៦- គគីវុក្ខាជាតិដើមឈើធំ មិនថាវស្សារដូវប្រាំង
មានម្លប់ត្រសុំត្រជាក់បាំង រស់ពេញកម្លាំងសែនសុខក្រៃ។

៧- ឧសតែសង្កែមិនមើលមាឋ ដើមស្គួចស្លឹកតូចប៉ុនមេដៃ
ប្រឹងលូតបបៀលយកល្បះដៃ គ្មានគិតសំចៃជីវិតខ្លួន។

៨- យប់ថ្ងៃគិតតែលូតបន្ត មានព្យុះភ្លៀងផ្គរបក់ជួបជួន
ប្រឹងទាំងត្រដងឥតដេកពួន រាងតូចស្រឡូនបោកបាក់អស់។

៩- ម្ដេចមិនប្រមាណខ្លួនឯងផង ជាតុជាល្បុះព្រៃជើងភ្នំសោះ
បង្កើតចិត្តប៉ងឥតស្រណោះ តាំងខ្លួនបង្អោះបង្ហាញរិទ្ធិ។

១០- ចុងក្រោយលទ្ធផលជួបគ្រោះភ័យ មិនទទួលស្គាល់សារជាតុពិត
ព្យុះវាយធ្លាក់ជីគ្មានអាណិត ខ្លួននេះអាគិតកើតពីអ្វី។

# យុវជនកម្ពុជា ៖ ទិវាយុវជនពិភពលោកជួយឲ្យជំនឿរីកចម្រើន តាមការអធិដ្ឋាននិងការជួបជុំ


ថតដោយ លីហៀង

តំណាងយុវជន យុវនារីទាំងបីភូមិភាគនៃព្រះសហគមន៍កាតូលិកកម្ពុជាចំនួន ៣៧នាក់ បានចូលរួមទិវាយុវជន ពិភពលោក នាពាក់កណ្ដាលខែកក្កដា ២០១៦ នៅប្រទេសប៉ូឡូញ ជាទឹកដីកំណើតនៃសន្តយ៉ូហានប៉ូលទីពីរ ដែលជាស្ថាបនិកនៃទិវាយុវជនពិភពលោក។ ទិវានេះ មានសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ចូលរួមជាអធិបតី និងមានយុវជនប្រមាណជាងពីរលាននាក់មកពី១៨៧ប្រទេសក្នុងពិភពលោកចូលរួមផងដែរ។

ក្នុងសប្ដាហ៍ទី១ នៃទិវាយុវជននេះ ពីថ្ងៃ២០-២៥ កក្កដា ក្រុមយុវជនកម្ពុជាបានចូលរួមជាមួយក្រុមយុវជននៅប៉ូឡូញនៅភូមិភាគគៀលសេ ដោយធ្វើដំណើរទៅកាន់ទីសក្ការៈ និងកន្លែងប្រវត្តិសាស្ត្រមួយចំនួនក្នុងតំបន់ មានដូចជាសារៈមន្ទីរផ្ទះបុរាណ វិមានរបស់លោកអភិបាលមណ្ឌលចាស់ជរានិងជនពិការ ដីព្រះពរ ដើម្បីសិក្សាស្វែងយល់ពីជំនឿ អរិយធម៌ និងវប្បធម៌នៃប្រទេសនេះ។ ក្នុងនោះក៏មានការអធិដ្ឋាន តាំងព្រះកាយព្រះគ្រីស្ត និងការដើរដង្ហែឈើឆ្កាងព្រះយេស៊ូរួមគ្នា។

យុវនារី ម៉ៅ ស្រីមុិច មកពីព្រះសហគមន៍កំពង់គោ ខេត្តកំពង់ធំ និយាយថា នេះជាលើកទីមួយដែលបានចូលរួម ហើយបានទទួលបទពិសោធន៍យ៉ាងច្រើនអំពីទំនាក់ទំនងជាមួយយុវជន និងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ស្រីមុិចបន្តថា "ខ្ញុំរំភើបមែនទែនដោយសារទំនាក់ទំនងនេះ ធ្វើឲ្យខ្ញុំភ្លេចអស់ភាពនឿយហត់ ដោយការដើរបណ្ដើរ ច្រៀងលើកតម្កើងសិរីរុងរឿងរបស់ព្រះជាម្ចាស់បណ្ដើរ"។ យុវតីរូបនេះថា ទាំងការអធិដ្ឋាន និងលេងកំសាន្តបានធ្វើឲ្យយុវជនមានជំនឿមាំមួន។

នៅសប្ដាហ៍ចុងក្រោយនៃទិវាយុវជននេះ ក្រុមយុវជនកម្ពុជា បានទទួលការអប់រំជាភាសាខ្មែរ ពីលោកអភិបាលអូលីវីយេនៃព្រះសហគមន៍ភូមិភាគភ្នំពេញនៅទីក្រុងក្រាកាវ។ ក្នុងការអប់រំនោះបានចែកជាបីប្រធានបទធំៗ គឺទីមួយអត្តសញ្ញាលើកលែងទោស ទីពីរ របៀបធ្វើឲ្យព្រះហឫទ័យប្រណីសន្ដោសរបស់ព្រះគ្រីស្តប៉ះបេះដូងរបស់ខ្ញុំ និងទីបី របៀបដែលយើងអាចធ្វើជាសាក្សីនៃធម៌មេត្តាករុណា។ លោកអភិបាល អូលីវីយេ មានប្រសាសន៍ថា ក្នុងប៉ុន្មានថ្ងៃកន្លងមកនេះ ព្រះសហគមន៍តូចរបស់យើងបានទទួលកម្លាំងច្រើន ដើម្បីឲ្យយើងបន្ត ប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗនៅពេលទៅកម្ពុជាវិញ។ លោកអភិបាលបានបន្តថា នេះជាពេលវេលាមួយដើម្បីឲ្យយើងមានបទពិសោធន៍ អំពីព្រះសហគមន៍សកល ឲ្យយើងយល់ថាព្រះសហគមន៍កម្ពុជារបស់យើងតូចមែន ប៉ុន្តែយើងមិននៅតែឯងយើងចូលនៅក្នុងព្រះសហគមន៍សកលរួមជាមួយសម្ដេចប៉ាប ឲ្យយើងទៅជាព្រះកាយព្រះគ្រីស្ត និងជាមេម្ប្រៅនៅក្នុងសង្គមបច្ចុប្បន្ននេះ ដើម្បីកសាងពិភពថ្មីដែលអាចរកឃើញសេចក្ដីស្រលាញ់ពិតៗ។

នៅចុងបញ្ចប់នៃទិវាយុវជននេះ យុវជនទាំងអស់ដែលមកពីបណ្ដាប្រទេសចំនួន១៨៧ ប្រទេសមានប្រមាណជាង ២លាននាក់បានចូលរួមជាមួយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ដោយមានការអធិដ្ឋានរួមគ្នាពេញមួយយប់។

សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ បានមានប្រសាសន៍ទៅកាន់យុវជនទាំងអស់ថា ព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់មានមុខដូចយុវជន ដែលអាចជំរុញឲ្យយើងចាកចេញពីភាពស្ងប់សុខផ្ទាល់ខ្លួន និងត្រៀមខ្លួនដើម្បីទទួលបងប្អូនឯទៀតៗ។ លោកបន្តថា អ្នកដែលមានចិត្តពោរពេញដោយក្ដីមេត្តាករុណា អាចជាទីជម្រកសម្រាប់មនុស្សគ្មានទីពឹងដូចជាអ្នកគ្មានផ្ទះសម្បែង អ្នកគ្មានម្ហូបអាហារ និងជនភៀសខ្លួន ជាដើម។

លោក ស៊ាន់ សារឿន ជាតំណាងយុវជនកម្ពុជាបានឲ្យដឹងថា "រយៈពេលពីរសប្ដាហ៍ក្នុងទិវាយុវជនពិភពលោកធ្វើខ្ញុំបានទទួលការអប់រំ និងទទួលបានបទពិសោធន៍នៃជំនឿជាច្រើន តាមរយៈសន្តយ៉ូហានប៉ូលទីពីរ និងសន្តីហ្វូស្ទីណា"។ លោកបានបន្តថា "ខ្ញុំសង្ឃឹមយុវជនយុវនារីកម្ពុជាយើង និងពាំនាំបទពិសោធន៍ក៏ដូចជា ជំនឿដែលបានទទួលទៅចែករំលែកជាមួយព្រះសហគមន៍នៅប្រទេសកម្ពុជា ជាពិសេសឲ្យយើងធ្វើជាគ្រីស្តបរិស័ទគំរូនៅក្នុងព្រះសហគមន៍ និងក្នុងសង្គមតាមរយៈជីវិតរស់នៅប្រចាំថ្ងៃរបស់យើងទាំងអស់គ្នា"។

ទិវាយុវជនពិភពលោកបានប្រារព្ធឡើងតាំងពីឆ្នាំ១៩៨៦ ដោយសម្ដេចប៉ាប យ៉ូហានប៉ូលទីពីរ ហើយបន្តរៀងរាល់៤ឆ្នាំម្ដង។ នេះជាលើកទី៥ ដែលយុវជនយុវនារីកម្ពុជាបានចូលរួមគឺចាប់តាំងពីឆ្នាំ២០០៥មក។ ទិវានេះនឹងធ្វើឡើងនៅប្រទេសប៉ាណាម៉ា នៅក្នុងឆ្នាំ២០១៩ខាងមុខនេះ។

*ដោយ ដាលីស*

**ព័ត៌មានសង្គម**

# អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ គឺជាឯកសារចម្បងសម្រាប់ការចុះឈ្មោះបោះឆ្នោត

ដំណើរការចុះឈ្មោះបោះឆ្នោតនៅកម្ពុជា កំពុងតែត្រូវបានដំណើរការដោយមន្ត្រីនៃគណកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយនៅក្នុងនោះអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានគេអះអាង ថាជាឯកសារចម្បងសម្រាប់ការចុះឈ្មោះបោះឆ្នោតថ្មីនេះ។

យោងទៅតាមសៀវភៅជំនួយស្មារតីសម្រាប់ការចុះឈ្មោះបោះឆ្នោត ដើម្បីរៀបចំបញ្ជីបោះឆ្នោតថ្មីឆ្នាំ២០១៦ បានឲ្យដឹងថា ឯកសារសំខាន់ៗសម្រាប់ចុះឈ្មោះបោះឆ្នោតតាមប្រព័ន្ធកុំព្យូទ័រ ដែលបានដំណើរការពីថ្ងៃទី០១ ខែកញ្ញា ដល់ថ្ងៃទី២៩ វិច្ឆិកា ២០១៦ ជារៀងរាល់ថ្ងៃ គឺមាន ៤ ប៉ុន្តែអត្តសញ្ញណបណ្ណសញ្ជាតិខ្មែរជាឯកសារសំខាន់ជាងគេ ក្រៅពីនោះរួមមានឯកសារបញ្ជាក់អត្តសញ្ញាណឯកសារបញ្ជាក់ទីលំនៅ និងលិខិតបញ្ជាក់ទីលំនៅ។

ប្រភពដដែលបានបន្តថា សម្រាប់អ្នកសុំចុះ ឈ្មោះបោះឆ្នោតទាំងឡាយណាដែលគ្មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរសម្រាប់ចុះឈ្មោះ គឺត្រូវមានឯកសារបញ្ជាក់អត្តសញ្ញាណ។ ហើយដើម្បីទទួលបានឯកសារនេះ គឺត្រូវមានឯកសារមួយនៅក្នុងចំណោមឯកសារ៦ បូកនឹងសាក្សី ២រូប រូបថតសាម៉ីខ្លួនចំនួន ២សន្លឹក គឺជាចំណុចសំខាន់។

ប្រភពដដែលបានបន្តថា ឯកសារមួយនៅក្នុងចំណោមឯកសារទាំង៦នេះ រួមមានសំបុត្រកំណើតច្បាប់ដើម ឬសេចក្ដីចម្លង ឬសំបុត្របញ្ជាក់កំណើត ឬព្រះរាជក្រិត្យផ្ដល់សញ្ជាតិខ្មែរ តាមការទាមទារសញ្ជាតិ ឬព្រះរាជក្រឹត្យផ្ដល់សញ្ជាតិដោយសញ្ជាតូបនីយកម្ម ឬសាលក្រមស្ថាពររបស់តុលាការ ឬឯកសារភស្តុតាងដែលបញ្ជាក់ថាសាម៉ីខ្លួនកើតមកពីឪពុកម្ដាយដែលមានសញ្ជាតិខ្មែរ។

ប្រភពដដែលបានបន្តថា ចំពោះអ្នកសុំចុះឈ្មោះបោះឆ្នោតទាំងឡាយណាដែលមានអត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ តែអាសយដ្ឋានផ្សេងពីកន្លែងដែលពួកគេសុំចុះឈ្មោះបោះឆ្នោត ពួកគាត់ត្រូវការឯកសារបញ្ជាក់ពីទីលំនៅ( សៀវភៅស្នាក់នៅ ) ឬសៀវភៅគ្រួសារ។

ម៉្យាងវិញទៀត ចំពោះអ្នកដែលគ្មានឯកសារជាសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារ តែបើចង់ចុះឈ្មោះបោះឆ្នោតនៅអាសយដ្ឋានផ្សេងពីអត្តសញ្ញាណប័ណ្ណ គឺពួកគាត់ត្រូវមានលិខិតបញ្ជាក់ទីលំនៅ។

*ដោយ : អរិយាបុត្រ*

# ព្រះសហគមន៍កំពង់ចាម បំផុសគំនិតយុវជនឲ្យចេះរៀបចំអនាគត



ថតដោយ ហៀសបុក

សិស្សានុសិស្សប្រមាណជា ៨០នាក់ មកពីមណ្ឌលយុវជនយុវនារីនៃព្រះសហគមន៍កាតូលិកកំពង់ចាម និងមកពីមណ្ឌលស្ទឹងត្រង់បានចូលរួមសិក្ខាសាលាតម្រង់ទិស កាលពីថ្ងៃទី១៦-១៨ សីហា ២០១៦ ដែលរៀបចំដោយគណៈកម្មការទទួលបន្ទុកផ្នែកអប់រំ នៃព្រះសហគមន៍កំពង់ចាម ។

តាមប្រសាសន៍របស់លោកផាន ប៉ូរ៉ា ជាអ្នកសម្របសម្រួលក្នុងកម្មវិធីវេទិកាតម្រង់ទិសនោះបានឲ្យដឹងថា ដោយមើលឃើញអំពីស្ថានភាពនៃការសិក្សារបស់យុវជនដែលកំពុងសិក្សា ទោះជានៅតាមសកលវិទ្យាល័យឬវិទ្យាល័យក្តី គឺគេមិនមានទំនុកចិត្តនឹងការរៀបចំទិសដៅនៅថ្ងៃអនាគតរបស់ខ្លួនច្បាស់លាស់ឡើយ ភាគច្រើនគឺរៀនតាមគ្នាមិនសូវមានគំនិតមើលឃើញអ្វីឲ្យទូលំទូលាយជាងអ្វីដែលពួកគេកំពុងមើលឃើញ ។

លោកបន្តថា សិក្ខាសាលានេះគ្រាន់តែបង្ហាញគំរុយខ្លះៗដើម្បីឲ្យគេរៀបចំសុបិនរបស់ពួកគេឲ្យវាក្លាយជាការពិត ។

ពិតណាស់ការជួយឲ្យយុវជន មានស្មារតីត្រៀមខ្លួន ចេះរៀបចំអនាគតឲ្យបានត្រឹមត្រូវ និងជោគជ័យ មានសារៈសំខាន់ណាស់ ដើម្បីឲ្យគេយល់ច្បាស់ពីគោលបំណង និងទិសដៅរបស់ខ្លួនក្នុងពេលអនាគតនោះ ។

លោកឧបដ្ឋាក សែសាត និយាយថា ពិតជាមានសារៈសំខាន់សម្រាប់ ។ យើងអាចជួយបំផុសគំនិតរបស់យុវជនម្នាក់ៗជាពិសេសគឺ សិស្សទាំងអស់ ឲ្យរិះគិតអំពីអនាគតរបស់ខ្លួន តើគេចង់ធ្វើអ្វី? ដើម្បីសម្រេចគោលដៅដែលខ្លួនចង់ធ្វើ តើត្រូវត្រៀមខ្លួន ត្រៀមលក្ខណៈសម្បត្តិយ៉ាងណាខ្លះ? តើអ្វីដែលចំណុចខ្លាំង និងខ្សោយរបស់ខ្លួន។ ព្រមទាំងផ្លាស់ប្តូរដោយពង្រឹងភាពខ្សោយរបស់ខ្លួន។

សិក្ខាសាលា រយៈពេលបីថ្ងៃនេះ តាមលោកផាន ប៉ូរ៉ា គឺបានបង្ហាញយុវជននូវគន្លឹះមានសារៈសំខាន់ជាច្រើនដូចជា ការរៀបចំផែនការសម្រាប់ជីវិតផ្ទាល់ខ្លួន ហើយនៅក្នុងការរៀបចំផែនការរបស់យើងបង្កើតឲ្យមានសុបិន។ ការរៀបចំផែនការ និងទស្សនៈវិស័យក្នុងការសិក្សា។ វិធីសាស្ត្រក្នុងការសម្រេចនូវគោលបំណង គឺការប្តេជ្ញាចិត្ត ការជំរុញ និងលើកទឹកចិត្តខ្លួនឯង។ វិធីសាស្ត្រ៥យ៉ាងក្នុងការដោះស្រាយទំនាស់ និងតួនាទីរបស់យុវជនសម្រាប់សង្គម។

យុវនារី ចាន់ ស្មី រៀនថ្នាក់ទី១០ កំពុងស្នាក់ក្នុងមណ្ឌលយុវនារីកំពង់ចាមបានឲ្យដឹងថានាងបានរៀនច្រើន គឺបានបំភ្លឺឲ្យនាងបើកគំនិត សំឡឹងមើលឲ្យឃើញផ្លូវវែងឆ្ងាយក្នុងការក្នុងការរៀបចំអនាគតរបស់ខ្លួន។ នាងនិយាយថា "កាលពីមុនខ្ញុំរៀន គឺគ្រាន់តែរៀនមិនដែលបានគិតអំពីថ្ងៃអនាគត់ថាចង់ធ្វើអ្វីនោះទេ? មិនដឹងថា មានកាងារជាច្រើនដែលកំពុងរងចាំអ្នកមានសមត្ថភាពពិតៗនោះទេ"។ នាងបន្តថា មានចំណុចជាច្រើនដែលនាងត្រូវកែប្រែ ដូចជាការរៀបចំផែនការក្នុងការសិក្សានិងការមានក្តីសុបិនថាខ្លួនឯងចង់រៀនអ្វីពេលចូលសកលវិទ្យាល័យ និងអ្វីដែលពិសេសនោះ គឺការតាំងចិត្តក្នុងការខិតខំប្រឹងប្រែងរៀនសូត្រ ចេះលើកទឹកចិត្តខ្លួនឯង បើទោះបីជាគ្មានអ្នកគាំទ្រឲ្យបន្តការសិក្សាក៏ដោយ។

ភ្លាមៗស្មីមានសុបិន និងបំណងចង់ក្លាយជាគ្រូពេទ្យម្នាក់។ ស្មីប្តេជ្ញាត្រូវតែសម្រេចឲ្យបាននូវក្តីស្រមៃនេះ គឺនាងនឹងខិតខំរៀនចាប់ពីពេលនេះទៅ និងយកអ្វីៗដែលទទួលបានពីសិក្ខាសាលានេះមកបំពេញនូវចំណុចដែលនាងខ្វះខាត។

តាមលោកផានប៉ូរ៉ា សិក្ខាសាលានេះមានការចូលរួមផ្តល់សក្ខីភាព និងបទពិសោធន៍ពីសំណាក់បុគ្គលិកមួយចំនួនដែលកំពុងបម្រើការងារនៅបណ្តាអង្គការ និងក្រុមហ៊ុននានា ពួកគេនិយាយអំពីការបរាជ័យក្នុងការសិក្សា និងការស្តារជីវិតឲ្យទទួលបានជោគជ័យ។

សិក្ខាសាលានេះ ត្រូវបានបិទវគ្គនៅមណ្ឌលយុវជនស្ទឹងត្រង់ ដែលស្ថិតនៅក្នុងភូមិបឹងដែង ឃុំព្រែកកក់ ស្រុកស្ទឹងត្រង់ ខេត្តកំពង់ចាម ដើម្បីជាការផ្លាស់ប្តូរបរិយាកាស និងទទួលកាសិក្សាបន្ថែម។

ព្រះសហគមន៍ភូមិភាគកំពង់ចាមបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យអប់រំដោយបង្កើតជាមណ្ឌលសិស្សស្នាក់នៅចំនួន១២កន្លែង សម្រាប់ទទួលសិស្សក្រីក្រដែលមកពីឆ្ងាយ និងឧបត្ថម្ភឲ្យគេបានរៀនបន្តនៅវិទ្យាល័យ។ ព្រះសហគមន៍ភូមិភាគកំពង់ចាមក៏មានវិទ្យាល័យអប់រំចំណេះទូទៅមួយផងដែលស្ថិតនៅក្នុងខេត្តព្រៃវែង។

*ដោយ រឿន ស្រីម៉ាច*

# ពិធីសម្ពោធន៍អាហារដ្ឋានមិត្តភាព

ព្រះវិហារព្រះកុមារយេស៊ូ នៃព្រះសហគមន៍បឹងទំពុន នារាជធានីភ្នំពេញ បានបើកសម្ពោធអាហារដ្ឋានមិត្តភាពខ្នាតតូចដែលមានទីតាំងស្ថិតក្នុងព្រះវិហារ កាលពីថ្ងៃទី២៨សីហានេះ ក្រោមវត្តមានរបស់លោកបូជាចារ្យសេន័យឆាល់ វ៉ាំងសង់ និងគ្រីស្តបរិស័ទទាំងជាតិនិងអន្តរជាតិប្រមាណជា ៧០នាក់។

លោកសេន័យឆាល់ វ៉ាំងសង់ជាបូជាចារ្យទទួលខុសត្រូវ នៅព្រះសហគមន៍កាតូលិកបឹងទំពុនបានមានប្រសាសន៍ថា អាហារដ្ឋាននេះ គឺធ្វើឡើងដើម្បីស្វែងរកប្រាក់ចំណេញសម្រាប់ជួយទ្រទ្រង់គ្រួសារក្រីក្រ ជនពិការ និងអ្នកគ្មានទីពឹង និងជួយដល់តម្រូវការផ្សេងៗរបស់ព្រះសហគមន៍។ លោកបូជាចារ្យបន្ថែមថា អាហារដ្ឋាននេះនឹងរឹតចំណងមិត្តភាពរវាងគ្រីស្តបរិស័ទនិងគ្រីស្តបរិស័ទ។

លោកបានបញ្ជាក់ថា "នេះគឺជាស្ថានមួយដែលឲ្យគ្រីស្តបរិស័ទមានទំនាក់ទំនងគ្នាមួយបែប ហើយក្នុងព្រះវិហារក៏មិនមានសភាពស្ងាត់ពេកដូចរាល់ដងគឺ គេតែងតែប្រញាប់ទៅផ្ទះវិញ មិនសូវឃើញមានអ្នកណាចំណាយពេលសន្ទនាជាមួយគ្នានោះទេ"។



លោកបូជាចារ្យរូបនេះ បានបន្ថែមទៀតថា អាហារដ្ឋាននេះអាចដំណើរការបានដោយមានការចូលរួមពីសំណាក់ក្រុមផ្សេងៗរបស់ព្រះវិហាររួមជាមួយនឹងយុវជនចូលរួមជួយសម្រួលក្នុងដំណើរការនៃការលក់រាល់ថ្ងៃអាទិត្យ។ លោកបន្តថា នេះជាសកម្មភាពមួយល្អដែលទាមទារឲ្យយើងចេះសហការគ្នា មានទំនាក់ទំនងជាមួយគ្នាល្អ និងជាសកម្មភាពសប្បុរសធម៌មួយជួយដល់សង្គម។

អាហារដ្ឋានមិត្តភាពរបស់ព្រះសហគមន៍កាតូលិកបឹងទំពុននេះ គឺបើកនៅរៀងរាល់ថ្ងៃអាទិត្យមានលក់អាហារសម្រន់ និងភេសជ្ជៈ មានទីតាំងស្ថិតនៅភូមិសន្សំកុសល សង្កាត់បឹងទំពុន ខណ្ឌមានជ័យ រាជធានីភ្នំពេញ។

# យុវជនកម្ពុជា ៖ អ្នកម្ដាយតេរេសាជាគំរូនៃការបម្រើព្រះជាម្ចាស់



រូបថតពីអ៊ីនធឺណែត

ថ្ងៃទី៤ កញ្ញានេះ នៅបុរីវ៉ាទីកង់ សម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ ប្រកាសជាផ្លូវការដោយបញ្ចូលឈ្មោះដូនជីម្នាក់ជាសន្ដី ដែលជាស្ថាបនិកក្រុមគ្រួសារមេត្តាករុណា នៅក្រុងកាល់គូតានៃប្រទេសឥណ្ឌា។

កិត្តិសព្ទរបស់ដូនជីរូបនោះត្រូវបានមនុស្សក្នុងពិភពលោកស្គាល់ និងកោតសរសើរនូវវីរភាពនៃជំនឿ និងកិច្ចការបម្រើចំពោះអ្នកតូចតាចបំផុតក្នុងចំណោមអ្នកតូចតាចជាងគេហើយត្រូវបានគេស្គាល់ថាអ្នកម្ដាយតេរេសានៃក្រុងកាល់គូតា។

នៅក្នុងប្រទេសកម្ពុជា ទោះបីជាដូនជីតេរេសាមិនដែលបានមកដល់ទឹកដីនេះក្ដី ក៏យុវជនជាច្រើនបានស្គាល់គាត់តាមរយៈក្រុមគ្រួសារបងប្រុសមេត្តាករុណា ដែលបានមានវត្តមានតាំងពីឆ្នាំ១៩៧៤ និងក្រោយមកក្នុងឆ្នាំ១៩៩១ មានក្រុមបងស្រីមេត្តាករុណា ក្រោមការអញ្ជើញរបស់អតីតអភិបាលព្រះសហគមន៍កាតូលិកភូមិភាគភ្នំពេញ គឺលោកអ៊ីវ៉ រ៉ាមូស។

លោករ៉ូ ប៉ូរ៉ា ជាគ្រីស្ដបរិស័ទម្នាក់បានឲ្យដឹងថាគាត់មិនដែលបានជួបផ្ទាល់ជាមួយអ្នកម្ដាយតេរេសាឡើយ គឺគ្រាន់តែស្គាល់តាមរយៈការអាន និងមើលអំពីជីវប្រវត្តិនិងកិច្ចការនានារបស់អ្នកម្ដាយតែប៉ុណ្ណោះ។ លោកប៉ូរ៉ាបន្ថែមថា អ្នកម្ដាយតេរេសាមាន គំរូដ៏ល្អជាច្រើនគឺគាត់ជាមនុស្សសាមញ្ញ មានចិត្តស្ងប់ គាត់ចេះប្រើជីវិតយ៉ាងមានក្ដីសុខក្នុងគ្រប់កាលៈទេសៈ។

នាក់ កញ្ញា ជាបុគ្គលិកធ្វើការនៅរោងពុម្ពមួយកន្លែងនៅភ្នំពេញបានឲ្យដឹងថានាងបានស្គាល់អ្នកម្ដាយតេរេសាតាមរយៈការមើលពីប្រវត្តិ និងវីដេអូរបស់គាត់និងបានធ្លាប់ទៅលេងផ្ទះបងស្រី នៃក្រុមគ្រួសារមេត្តាករុណានៅទីក្រុងភ្នំពេញ។ កញ្ញាជាគ្រីស្ដបរិស័ទកាតូលិកមកពីខេត្តកំពតបានបន្តថា អ្នកម្ដាយតេរេសាជាអ្នកម្ដាយមួយរូបដែលលះបង់ពេលវេលាកម្លាំងកាយជួយដល់អ្នកក្រ អ្នកដែលគេបោះបង់ចោល ក្មេងកំព្រា អ្នកជំងឺ។

រឿងរ៉ាវសង្គមកម្ពុជាសព្វថ្ងៃជាពិសេសភាពក្រីក្រ ធ្វើឲ្យកញ្ញានឹកឃើញដល់បេសកកម្មរបស់អ្នកម្ដាយតេរេសានៅប្រទេសឥណ្ឌា។ កញ្ញាបានឲ្យដឹងទៀតថា "អ្នកម្ដាយជា hero ( មនុស្សអស្ចារ្យ ) របស់ខ្ញុំ។ អ្វីដែលគាត់ជួយគេបានគឺគាត់ជួយ។ គាត់មិនគិតថាជីវិតរបស់គាត់ទៅជាអ្វីទេ"។ គំរូនេះធ្វើឲ្យកញ្ញាយកមកអនុវត្តក្នុងជីវិត។ កញ្ញា "កាលនៅរៀនខ្ញុំធ្វើសកម្មភាពខ្លះៗជាមួយក្រុមបងស្រីមេត្តាករុណាដែរ។ ដល់ពេលឥឡូវ ខ្ញុំក៏ឆ្លៀតពេលសួរសុខទុក្ខស្រ្ដីមេម៉ាយ ស្ត្រីធ្វើការសំណង់តាមដែលអាចធ្វើបាន"។

លោកកាន់ ប៊ុយ ជានិស្សិតមួយរូបបានឲ្យដឹងថា "ខ្ញុំយល់ថា គំរូដ៏សំខាន់បំផុតរបស់អ្នកម្ដាយតេរេសា ឬសន្ដីតេរេសានៅកាល់កូតា គឺការបម្រើជនទុគ៌តដោយសេចក្ដីស្រឡាញ់ដ៏អស្ចារ្យដោយគ្មានការវិនិច្ឆ័យ និងការរើសអើងចំពោះមនុស្សទាំងឡាយជាពិសេសអ្នកតូចតាចជាងគេបំផុតដែលសង្គមបោះបង់ចោល ដូចជាអ្នកជម្ងឺ និងកុមារពិការជាដើម"។ លោកប៊ុយបន្តថា ស្នាដៃរបស់អ្នកម្ដាយតេរេសាសបញ្ជាក់ពីការអស្ចារ្យនៃជំនឿកាតូលិកដែលមិនជំទាស់ទៅនឹងវប្បធម៌ប្រពៃណី និងសាសនានានា ហើយនាំមនុស្សឲ្យឆ្លងកាត់ការប្រកាន់ពូជសាសន៍ និងពណ៌សម្បុរនយោបាយជាដើម។

គំរូដ៏សំខាន់របស់អ្នកម្ដាយសម្រាប់លោក គឺជាការធ្វើបុណ្យដ៏ត្រឹមត្រូវជាមួយអ្នកក្រដែលត្រូវការជំនួយជាចាំបាច់នៅចំពោះមុខ ដោយមិនត្រូវការចិញ្ចឹមមនុស្សដែលឆ្លៀតឱកាសកេងប្រវញ្ចដ៏ឈ្លាសវៃ។ ប៊ុយបានឲ្យដឹងទៀតថា "តាមរយៈគំរូរបស់អ្នកម្ដាយតេរេសានេះ ធ្វើឲ្យខ្ញុំចង់បម្រើអ្នកដទៃទៅតាមអំណោយទាន និងទេពកោសល្យ ដែលបានមកពីព្រះជាម្ចាស់ ដូចជាការបង្រៀនចំណេះដឹងទូទៅ និងអប់រំជំនឿជាដើម"។

សព្វថ្ងៃ នៅក្នុងប្រទេសកម្ពុជាក្រុមគ្រួសារបងស្រីនិងបងប្រុសមេត្តាករុណាមានបួនទីតាំង ដែលមាន៣កន្លែងនៅភ្នំពេញ និងមួយទៀតនៅខេត្តសៀមរាប។ បេសកកម្មរបស់ក្រុមនេះមានដូចជា ផ្ទះសម្រាប់ទទួលកុមារកំព្រា និងកុមារផ្ទុកជំងឺ ជនពិការបញ្ញាស្មារតី ផ្ទះស្នាក់នៅសម្រាប់កុមារដើម្បីសិក្សានៅសាលារដ្ឋ ការចែកថ្នាំពេទ្យដល់ប្រជាជនក្រីក្រ និងការចុះសួរសុខទុក្ខពិនិត្យសុខភាព ផ្ដល់ថ្នាំ និងលើកទឹកចិត្តដល់ទណ្ឌិតនៅក្នុងពន្ធនាគារ។

អ្នកម្ដាយតេរេសា មានដើមកំណើតជាជនជាតិអាល់បានី ប្រសូតនៅថ្ងៃទី២៦ សីហា ១៩១០ ស្ថិតក្នុងគ្រួសារអភិជនមួយ។ គាត់មានឈ្មោះដើមថា អាញ៉េស កុនចា បូហាស្ស៊ី ( Agnes GonxhaBojaxhiu )។ គាត់បានចូលរួមក្នុងក្រុមគ្រួសារបងស្រី ឡូរ៉េតូនៅខែកញ្ញា ឆ្នាំ ១៩២៨ ហើយត្រូវបានបញ្ជូនឲ្យទៅបំពេញបេសកកម្មនៅប្រទេសឥណ្ឌា។ ក្រោយពីបានបំពេញការងារមួយរយៈ បងស្រីតេរេសាបានមើលឃើញនូវតម្រូវការមួយផ្សេងទៀតរបស់ប្រជាជន នៅក្រុងកាល់គូតាដែលអាចហៅបានថា ជា "ការចាត់ចែង" ពីព្រះជាម្ចាស់ ដើម្បីចាកចេញពីវត្តអារាមរបស់គាត់ និងរស់នៅក្នុងចំណោមអ្នកក្រីក្រ។

អ្នកម្ដាយតេរេសាបានចាប់ផ្ដើមធ្វើការដោយការបង្រៀនកុមារក្រីក្រ និងព្យាបាលអ្នកជំងឺនៅក្នុងផ្ទះរបស់ពួកគេ។ មួយឆ្នាំក្រោយមកអតីតសិស្សមួយចំនួនរបស់គាត់បានមកចូលរួមជាមួយគាត់ធ្វើឲ្យបេសកកម្មរបស់គាត់កាន់តែមានកំលាំង ហើយពួកគេទទួលបុរសស្ត្រីនិងក្មេងដែលជិតស្លាប់នៅតាមប្រឡាយទឹកយកមកព្យាបាលទាំងអស់។

ក្នុងឆ្នាំ១៩៥០ អ្នកម្ដាយថេរេសាបានបង្កើតក្រុមបងស្រីមេត្តាករុណា ក្នុងភូមិភាគកាល់គូតា និងបន្ទាប់មកបានបង្កើតក្រុមបងប្រុសមេត្តាករុណា។ កិច្ចការនិងជីវិតខាងផ្លូវវិញ្ញាណរបស់អ្នកម្ដាយថេរេសា បានបន្តទាក់ទាញការ កោតសរសើរ នៅទូទាំងសកលលោក។ គាត់បានទទួលមរណភាពនៅថ្ងៃទី០៥ កញ្ញា ១៩៩៧ ក្នុងជន្មាយុ៨៧។ អ្នកម្ដាយថេរេសា ត្រូវបានប្រកាសយ៉ាងឱឡារិកថា ជាបុគ្គលប្រកបដោយ សុភមង្គលដោយសន្តសម្ដេចប៉ាបយ៉ូហាន ប៉ូលទី២ នៅថ្ងៃទី១៩ ខែតុលាឆ្នាំ២០០៣និងត្រូវបានប្រកាសជាសន្ដីតេរេសានៃក្រុងកាល់គូតា ដោយសម្ដេចប៉ាប ហ្វ្រង់ស៊ីស្កូ នៅថ្ងៃទី០៤ កញ្ញា ២០១៦នេះ។

*ដោយ : កញ្ញា*



រូបថតពីអ៊ីនធឺណែត



### ថ្ងៃអាទិត្យទី២៣ ក្នុង រដូវធម្មតា ត្រូវនឹងថ្ងៃទី ៤ ខែកញ្ញា ២០១៦

គម្ពីរដំណឹងល្អតាមលោកលូកា ១៤:២៥-៣៣

*"បើអ្នកណាចង់មកតាមខ្ញុំ តែមិនស្រឡាញ់ខ្ញុំខ្លាំងជាងឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនទេ អ្នកនោះពុំអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ។ អ្នកណាមិនលីឈើឆ្កាងរបស់ខ្លួនមកតាមខ្ញុំទេ អ្នកនោះក៏ពុំអាចធ្វើជាសាវ័ករបស់ខ្ញុំបានដែរ។ ដូច្នេះក្នុងចំណោមបងប្អូន បើអ្នកណាមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេ អ្នកនោះមិនអាចធ្វើជាសាវ័ករបស់ខ្ញុំបានឡើយ"។*

ធម្មតា មនុស្សយើងសប្បាយចិត្តដោយរស់នៅជាមួយឪពុកម្ដាយ ដោយមានគ្រួសារ មានកូន ហើយដោយមានទ្រព្យសម្បត្តិជាច្រើនថែមទៀតផង គឺមនុស្សយើងចង់បានប្រាក់ចាយ ចង់បានផ្ទះនៅ ចង់មានម៉ូតូឬឡានជិះ។ល។ តែនៅថ្ងៃនេះ ព្រះយេស៊ូមានព្រះបន្ទូលធ្ងន់ៗ និងពិបាកទទួលណាស់គឺថា យើងក៏ត្រូវស្រឡាញ់ព្រះអង្គលើសអ្នកណា ទាំងអស់ ហើយប្រសិនបើយើងមិនលះបង់អ្វីៗទាំងអស់ដែលខ្លួនមានទេនោះ យើងមិនអាចធ្វើជាសាវ័ករបស់ព្រះអង្គបានឡើយ។ យើងគ្មានជម្រើសផ្សេងទៀត គឺត្រូវលះបង់អ្វីទាំងអស់ ដើម្បីភ្ជាប់ចិត្តនឹងព្រះគ្រីស្ត ដែលបំពេញ បំណងទាំងអស់របស់យើង។ ត្រង់នេះ យើងមានគំនិតខុសស្រឡះពីមនុស្សឯទៀតៗទាំងអស់ក្នុងលោកនេះ។ យើងដឹងច្បាស់ថាយើងមិនអាចស្រឡាញ់ព្រះយេស៊ូបែបនេះបានទេ តែជាឧត្តមគតិរបស់យើងជាគ្រីស្តបរិស័ទ។ ជួនកាល ពេលយើងចង់ចូលគ្រីស្តសាសនា ឪពុកម្ដាយ ញាតិមិត្តនាំគ្នាស្ដីបន្ទោសយើងថា ក្បត់ប្រពៃណីសាសនា របស់ខ្មែរ។ ពេលនោះយើងត្រូវជ្រើសរើស តើយើងស្រឡាញ់ព្រះយេស៊ូខ្លាំងជាងគាត់ឬយ៉ាងណា? យើងបានរក មាគ៌ាប្លែកទៅកាន់ជីវិតដ៏ពេញលេញរួមជាមួយព្រះយេស៊ូ។ សូមព្រះអង្គប្រែចិត្តគំនិតរបស់យើង។

### ថ្ងៃអាទិត្យទី២៤ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី១១ ខែកញ្ញា ២០១៦

*ព្រះជាម្ចាស់ជាព្រះដ៏ខ្ពង់ខ្ពស់បំផុត មានអំណរសប្បាយ ដោយមានមនុស្សបាបតែម្នាក់ ប្រែចិត្តគំនិត ខ្លាំងជាងព្រះអង្គសប្បាយនឹងមនុស្សសុចរិតកៅសិបប្រាំបួននាក់ ដែលមិនត្រូវការប្រែ ចិត្តគំនិត។*

ថ្ងៃនេះ ព្រះយេស៊ូរំឭកឲ្យយើងដឹងថា ព្រះបិតាស្រឡាញ់មនុស្សទាំងអស់ហួសពីការស្មានរបស់យើង។ ព្រះអង្គរៀបរាប់រឿងកូនពីរនាក់ គឺកូនពៅដែលរត់ចោលឪពុក ចាយវាយទ្រព្យសម្បត្តិអស់ រួចត្រឡប់មករកឪពុក ដើម្បីឲ្យឆ្អែតក្រពះ។ កូនមួយទៀត ជាកូនច្បងបានធ្វើតាមបញ្ជារបស់ព្រះបិតាក្នុងគ្រប់ប្រការ តែវាគ្មានចិត្តស្រឡាញ់ឪពុក ទេ វានៅតែខ្លាចឪពុកដូចជាខ្លាចម្ចាស់។ តែព្រះបិតាស្រឡាញ់កូនទាំងពីរនាក់ ទាំងកូនដែលប្រព្រឹត្តខុសវិន័យ គឺកូនដែលមានបាបពេញខ្លួន ទាំងកូនច្បងដែលពឹងផ្អែកលើបុណ្យកុសលរបស់គេ។ យើងត្រូវដឹងថា ទោះជាយើងធ្វើ អំពើល្អតាមធម្មវិន័យយ៉ាងត្រឹមត្រូវក្ដី ក៏យើងមិនដែលសមនឹងព្រះហឫទ័យស្រឡាញ់របស់ព្រះអង្គចំពោះយើង។ ត្រង់នេះយើងប្លែកពីពុទ្ធបរិស័ទដែលខិតខំសន្សំបុណ្យសន្សំកុសល ដើម្បីសង្គ្រោះខ្លួនដោយពឹងលើខ្លួនឯង។ កូនទាំងពីរនាក់នេះ ត្រូវតែប្រែចិត្តគំនិត គឺត្រូវផ្ញើជីវិតទាំងស្រុងលើព្រះបិតាដែលមានមេត្តាករុណាដល់ខ្លួន។ យើងក៏មានចិត្តមេត្តាករុណាដល់អ្នកដទៃ លុះត្រាតែយើងមានបទពិសោធន៍អំពីព្រះអង្គមេត្តាករុណាដល់យើង។ កុំអស់សង្ឃឹមឲ្យសោះ ទោះបីយើងប្រព្រឹត្តអំពើបាបជាច្រើនក្ដី ក៏ព្រះបិតានៅតែស្រឡាញ់យើងជានិច្ច យើងត្រូវផ្ញើជីវិត ទាំងស្រុងលើព្រះបិតា ព្រះអង្គរង់ចាំទទួលយើងជានិច្ច។

### ថ្ងៃអាទិត្យទី ២៥ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី១៨ ខែកញ្ញា ២០១៦

*មនុស្សក្នុងលោកនេះតែងតែប៉ិនប្រសប់រកស៊ីជាមួយគ្នា ជាងអស់អ្នកដែលស្គាល់ពន្លឺរបស់ព្រះជាម្ចាស់ទៅទៀត។ ចូរយកទ្រព្យសម្បត្តិលោកីយ៍ដែលបញ្ឆោតចិត្តនេះ ទៅធ្វើទានដើម្បីឲ្យមានមិត្តភក្ដិច្រើន។ ពេលណាទ្រព្យទាំងនោះរលាយសូន្យទៅ មិត្តភក្ដិទាំងនោះនឹងទទួលបងប្អូននៅក្នុងដំណាក់របស់ព្រះជាម្ចាស់។*

ព្រះយេស៊ូប្រៀនប្រដៅប្រហែលនឹងព្រះពុទ្ធជាព្រះបរមគ្រូដែរ គឺយើងត្រូវសុខចិត្តធ្វើបុណ្យធ្វើទានដល់អ្នកក្រីក្រ ទើបយើងនឹងមានសម្បត្តិសួគ៌ដែលស្ថិតនៅគង់វង្សរហូត។ ព្រះអង្គអញ្ជើញយើងឲ្យខិតខំសន្សំទ្រព្យសួគ៌ ដូចយើងខិតខំ រកស៊ីចិញ្ចឹមជីវិតដែរ។ តើអ្វីខ្លះសំខាន់ជាងគេប្រចាំជីវិត? គឺយកចិត្តទុកដាក់នឹងអ្នកដែលរស់នៅជុំវិញយើងនិង ស្រឡាញ់គេ។ យើងយកចិត្តទុកដាក់ជួយអ្នកដទៃ ជាពិសេសអ្នកក្រជាងយើង ព្រោះអ្នកទាំងនោះជារូបតំណាង របស់ព្រះគ្រីស្ត។ យើងមិនគ្រាន់តែរង់ចាំទទួលអំណោយឬប្រាក់បៀវត្សពីព្រះសហគមន៍ប៉ុណ្ណោះទេ តែយើងត្រូវជួយគេតាមរបៀបដែលយើងអាចធ្វើបាន គឺចែកអំណរសប្បាយដល់គេ ទៅលេងគេ ទូន្មានគេ ញញឹមដាក់គេ សម្ដែងសេចក្ដីស្រឡាញ់ដល់គេ ចែកទានដល់អ្នកក្រ។ ល។និង។ល។។ ក្នុងប្រទេសយើងក៏ដូចនៅក្នុងប្រទេសដទៃ ច្រើនឯទៀតៗ អ្នកមានតែងតែជិះជាន់អ្នកក្រីក្រដូចព្យាការីអេម៉ូសធ្លាប់ចែងជាង២៧០០ ឆ្នាំកន្លងមក។ យើងជាគ្រីស្តបរិស័ទខិតខំបង្កើតពិភពលោកថ្មីប្រកបដោយយុត្តិធម៌និងភាតរភាព គឺក្នុងពិភពលោកថ្មីនោះ មនុស្សរស់នៅ ដូចបងប្អូន ដោយចែកអ្វីដែលខ្លួនមានដល់អ្នកដទៃ និងយកចិត្តទុកដាក់នឹងគ្នា។ គ្រីស្តបរិស័ទមិនគ្រាន់ តែជាអ្នកសូត្រគម្ពីរ តែជាអ្នកដែលរាប់អ្នកដទៃទុកជាបងប្អូន និងជាបុត្រធីតារបស់ព្រះបិតា។ កុំចាំឲ្យរដ្ឋឬអ្នកមាន ជួយអ្នកក្រីក្រទេ សូមចាប់ផ្ដើមខ្លួនឯងចុះ។ រៀងរាល់យប់មុនចូលដំណេក នៅពេលអធិដ្ឋាន ត្រូវសួរខ្លួនឯងថា តើនៅថ្ងៃនេះ ខ្ញុំបានចែកអ្វីខ្លះដល់អ្នកដទៃ?

### ថ្ងៃអាទិត្យទី២៦ ក្នុងរដូវធម្មតា ត្រូវនឹងថ្ងៃទី២៥ ខែកញ្ញា ២០១៦

*"កូនអើយ!ចូរនឹកចាំថា កាលកូនមានជីវិតនៅឡើយ កូនស្គាល់តែសប្បាយ រីឯឡាសារវិញ គ្នាស្គាល់តែទុក្ខ។ ឥឡូវនេះ ឡាសារបានសុខក្សេមក្សាន្តហើយ តែកូនវិញកូនត្រូវឈឺចុកចាប់។*

ព្រះយេស៊ូរៀបរាប់រឿងអ្នកមានម្នាក់ដែលគិតតែពីរកស៊ី តែមិនរវីរវល់នឹងអ្នកក្រីក្រដែលរស់នៅក្បែរផ្ទះរបស់គាត់។ លោកមិនមែនជាមនុស្សខិលខូចទេ តែលោកមិនរវីរវល់នឹងអ្នកដទៃ គាត់គិតតែពីសន្សំទ្រព្យសម្បត្តិទុកជាកិច្ចដ៏សំខាន់ជាងគេប្រចាំជីវិតគេ។ រួចគាត់ត្រូវស្លាប់ ទុកចោលសម្បត្តិទាំងនោះទៅ។ រីឯម្នាក់ទៀត គឺឡាសារជាអ្នកក្រីក្រ រហូតដល់មានឆ្កែមកលិតដំបៅគាត់។ ក្នុងគម្ពីរគ្មានចែងថា គាត់ជាមនុស្សល្អទេ តែគ្នាធ្លាក់ខ្លួនក្រ គាត់ផ្ញើជីវិតលើអ្នកដទៃ និងផ្ញើជីវិតលើព្រះជាម្ចាស់ដែរ។ លោកលូកាចូលចិត្តចែងថា នៅលោកខាងមុខ យើងនឹងមានវាសនាផ្ទុយនឹងវាសនារបស់យើងនៅក្នុងលោកនេះ។ នៅថ្ងៃនេះ យើងត្រូវតែសួរខ្លួនឯងថា តើខ្ញុំយកចិត្តទុកដាក់នឹងអ្នកដទៃយ៉ាងណា? ក្នុងអត្ថបទទីមួយព្យាការីអេម៉ូស ស្ដីបន្ទោសអ្នកមានដែលមិនគិតអ្វីក្រៅពីចង់បានចំណេញ។ យើងជា គ្រីស្តបរិស័ទខ្មែរ ត្រូវយកចិត្តទុកដាក់ រកយុត្តិធម៌ក្នុងសង្គម។ មុនដំបូង យើងរកស៊ីដោយមិនស៊ីសំណូក គឺរកស៊ីត្រឹមត្រូវ។ បន្ទាប់មក យើងគិតគូដល់ការកសាងយុត្តិធម៌ក្នុងសង្គម។ កុំនិយាយថា នេះជាការងាររបស់គេ ខ្ញុំនៅម្នាក់ឯងធ្វើមិនកើត។ ខ្ញុំចាប់ផ្ដើមរកយុត្តិធម៌ក្នុងក្រុមគ្រួសារ និងក្នុងភូមិសិន។



# វិទ្យាស្ថានសន្តប៉ូល

អាសយដ្ឋាន៖ ភូមិអង្គគីរ ឃុំតាភេម ស្រុកត្រាំកក់ ខេត្តតាកែវ
Tel: 032 639 0002/ 032 639 0003 | E: spi.takeo@gmail.com | W : www.spi.edu.kh

## ថ្នាក់បរិញ្ញាបត្រ

**មហាវិទ្យាល័យព័ត៌មានវិទ្យា**
**Faculty of Information Technology**

- វិស្វកម្មកម្មវិធី Software Engineering
- ទូរគមនាគមន៍ និងបណ្តាញ Telecommunication and Network

**ដេប៉ាតឺម៉ង់អក្សរសាស្ត្រអង់គ្លេស**
**Department of English Literature**

- អប់រំភាសាអង់គ្លេស Teaching English as Foreign Language
- ភាសាអង់គ្លេសសម្រាប់ទំនាក់ទំនង English for Communication

**ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍**
**Department of Tourism Management**

- គ្រប់គ្រងទេសចរណ៍ Tourism Management

**ដេប៉ាតឺម៉ង់ក្សេត្រសាស្ត្រ**
**Department of Agronomy**

- ក្សេត្រសាស្ត្រ Agronomy

**ដេប៉ាតឺម៉ង់សង្គមកិច្ច**
**Department of Social Work**

- សង្គមកិច្ច Social Work

## ថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស

- **អភិវឌ្ឍន៍កម្មវិធីកុំព្យូទ័រ** Software Development
- **គ្រប់គ្រងប្រព័ន្ធ និងបណ្តាញកុំព្យូទ័រ** System and Network Administration
- **បង្រៀនភាសាអង់គ្លេស** English Language
- **សណ្ឋាគារ និងបដិសណ្ឋារកិច្ច** Hotel and Hospitality
- **ផលិតកម្មដំណាំឈើហូបផ្លែ និងបន្លែ** Fruit and Vegetable Crop Production
- **ជំនាញកែច្នៃអាហារ** Food Processing
- **ប្រព័ន្ធកសិកម្មចម្រុះ** Integrated Farming System

## លក្ខខណ្ឌចូលរៀន

១. បេក្ខជនត្រូវមានសញ្ញាបត្រទុតិយភូមិ (ជាប់ថ្នាក់ទី១២) ឬសញ្ញាបត្រដែលមានតម្លៃស្មើ សម្រាប់ចូលរៀនថ្នាក់បរិញ្ញាបត្រ

២ បេក្ខជនធ្លាក់ថ្នាក់ទី១២អាចចូលរៀនថ្នាក់បរិញ្ញាបត្ររងជំនាញបច្ចេកទេស




**ចាប់ផ្តើមលក់ពាក្យ និងទទួលពាក្យ**
**ចាប់ពីថ្ងៃជូនដំណឹងនេះតទៅ**

- ចូលរៀនវគ្គបំប៉ន ខែកញ្ញា ឆ្នាំ២០១៦
- ចូលរៀនឆមាសទី១ ខែវិច្ឆិកា ឆ្នាំ២០១៦